# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

# ផែនការសកម្មភាព

## ដើម្បីបង្ការ ទប់ស្កាត់ និងឆ្លើយតបការកេងប្រវ័ញ្ច
## ផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ
## ២០២១-២០២៥

ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ

ឆ្នាំ២០២០

# អារម្ភកថា

រាជរដ្ឋាភិបាលដឹកនាំដោយសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាបានបោះជំហានទៅមុខក្នុងការស្តារសង្គម និងសេដ្ឋកិច្ចឡើងវិញដែលក្នុងពីរទសវត្សរ៍ចុងក្រោយនេះ សម្រេចកំណើនសេដ្ឋកិច្ចជាបន្តបន្ទាប់ និងកំពុងសមាហរណកម្មខ្លួនចូលក្នុងតំបន់ និងពិភពលោកដែលធ្វើឱ្យកម្ពុជាទទួលបានឱកាសជាច្រើនក្នុងការកសាង និងអភិវឌ្ឍប្រទេសជាតិ។ ស្របពេលជាមួយគ្នានេះរាជរដ្ឋាភិបាលនីតិកាលទី៦ នៃរដ្ឋសភាបានដាក់ចេញនូវយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ ដោយធ្វើការវិភាជន៍ធនធានបន្ថែមដល់វិស័យសុខាភិបាល អប់រំ សង្គមកិច្ច និងវិស័យផ្សេងៗទៀតសម្រាប់ជំរុញការអភិវឌ្ឍធនធានមនុស្ស រួមទាំងការអភិវឌ្ឍកុមារ សំដៅសម្រេចឱ្យបាននូវគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ២០១៦-២០៣០ ទន្ទឹមនឹងនេះកម្ពុជាបានត្រៀមខ្លួនជាស្រេចក្នុងការចូលរួមក្នុងបដិវត្តឧស្សាហកម្មទី៤ ដែលផ្តោតជាពិសេសលើវិស័យបច្ចេកវិទ្យា ដែលពិភពលោកកំពុងប្រើប្រាស់សម្រាប់វិស័យនយោបាយ សេដ្ឋកិច្ច និងសង្គមកិច្ចបានយ៉ាងមានប្រសិទ្ធភាព។ ការរីកចម្រើនផ្នែកបច្ចេកវិទ្យាព័ត៌មានបានជំរុញដល់ការរីកលូតលាស់ ការងារ នយោបាយ សេដ្ឋកិច្ច និងសង្គមកិច្ច ដែលធ្វើឱ្យកម្ពុជាមានទំនាក់ទំនងជាមួយបណ្តាប្រទេសក្នុងតំបន់ និងពិភពលោកថែមទៀតផង។

ការរីកចម្រើនផ្នែកបច្ចេកវិទ្យាព័ត៌មានបង្កើតឱ្យមានការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ ដែលជាទម្រង់ថ្មីមួយកំពុងរាលដាលនៅលើពិភពលោករួមទាំងកម្ពុជាផងដែរ។ ដោយមើលឃើញបញ្ហាប្រឈម និងផលប៉ះពាល់ពីការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញនេះ រាជរដ្ឋាភិបាលកម្ពុជាបានសម្រេចចូលជារដ្ឋភាគីហត្ថលេខីនៃសេចក្តីថ្លែងការណ៍សកម្មភាពសកល (WePROTECT) ដែលបានចុះហត្ថលេខាក្នុងកិច្ចប្រជុំកំពូលជាសកលនៅទីក្រុងអាប៊ុយដាប៊ីកាលពីឆ្នាំ២០១៥ ដែលមានក្រសួងមហាផ្ទៃជាអ្នកសម្របសម្រួល។ សេចក្តីថ្លែងការណ៍សកម្មភាពសកលនេះ បានបង្កើតយន្តការឆ្លើយតបថ្នាក់ជាតិគំរូ (MNR) ដែលសង្កត់ធ្ងន់លើសារសំខាន់នៃការចូលរួមរបស់អ្នកពាក់ព័ន្ធនានា និងកំណត់នូវឧស្សាហកម្មពាក់ព័ន្ធធំៗនៅក្នុងកិច្ចការពារកុមារតាមប្រព័ន្ធអនឡាញ។ កម្ពុជាបានចូលជាសមាជិកនៃប្រទេសភាពជាដៃគូសកលដើម្បីលុបបំបាត់អំពើហិង្សាលើកុមារ (Pathfinding Country) នៅថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១៩ និងបានរៀបចំផែនការសកម្មភាពទប់ស្កាត់ និងឆ្លើយតបចំពោះអំពើហិង្សាលើកុមារ ឆ្នាំ២០១៧-២០២១ ដែលបានលើកទឹកចិត្តឱ្យមានសកម្មភាពទប់ស្កាត់អំពើហិង្សា និងកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញផងដែរ។ បន្ថែមពីនេះ ប្រមុខរាជរដ្ឋាភិបាលកម្ពុជាបានចូលរួមអនុម័តលើសេចក្តីថ្លែងការណ៍នាកិច្ចប្រជុំកំពូលនៅថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១៩ ក្នុងគោលបំណងអំពាវនាវឱ្យរដ្ឋជាសមាជិកអាស៊ានទាំងអស់ប្រើប្រាស់បទដ្ឋានកម្រិតខ្ពស់ ដើម្បីការពារកុមារទាំងអស់នៅក្នុងអាស៊ានពីការកេងប្រវ័ញ្ច និងរំលោភបំពានផ្លូវភេទតាមប្រព័ន្ធអនឡាញ។

ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ បានចេញផ្សាយរបាយការណ៍វិភាគស្ថានភាពដំបូងស្តីពីការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ នៅថ្ងៃទី១០ ខែមករា ឆ្នាំ២០២០ បានប៉ាន់ប្រមាណឃើញថា ការប្រើប្រាស់ឬភ្ជាប់ប្រព័ន្ធអ៊ិនធឺណិតនៅកម្ពុជា បាននិងកំពុងកើនឡើងយ៉ាងខ្លាំងនៅអំឡុងពេលប៉ុន្មានឆ្នាំកន្លងមកនេះ ផ្អែកតាមការព្យាករណ៍ និន្នាការនេះ នឹងកើនឡើងបន្តទៀតនាពេលអនាគតនៅកម្ពុជា។ ការវិភាគស្ថានភាពដំបូងស្តីពីការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញនេះ មានគោលបំណងកំណត់អនុសាសន៍ផ្អែកលើភស្តុតាងដែលអាចដាក់ចេញជាសកម្មភាពជាក់ស្តែងសម្រាប់អន្តរាគមន៍ជាក់លាក់នៅកម្ពុជា ដោយផ្អែកលើក្របខណ្ឌគំរូនៃការឆ្លើយតបថ្នាក់ជាតិ (MNR) នៃសេចក្តីថ្លែងការណ៍សកម្មភាពសកល (WePROTECT) ដែលនឹងបញ្ចូលទៅក្នុងផែនការសកម្មភាពដើម្បីបង្ការ ទប់ស្កាត់ និងឆ្លើយតបការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ។

ឆ្លើយតបទៅនឹងអនុសាសន៍នៃរបាយការណ៍វិភាគស្ថានភាពដំបូង ស្តីពីការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ រួមជាមួយក្រុមការងារបច្ចេកទេសការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ (OCSETWG) ដែលមានសមាជិកមកពីក្រសួង ស្ថាប័នពាក់ព័ន្ធ អង្គការមិនមែនរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍នានា បានចូលរួមរៀបចំផែនការសកម្មភាពដើម្បីបង្ការ ទប់ស្កាត់ និងឆ្លើយតបការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ ឆ្នាំ២០២១-២០២៥។ ផែនការនេះ បានកំណត់គោលដៅយុទ្ធសាស្រ្តអាទិភាពចំនួន៦ ស្របជាមួយយន្តការឆ្លើយតបថ្នាក់ជាតិគំរូ (MNR) នៃសេចក្តីថ្លែងការណ៍សកម្មភាពសកល (WePROTECT) និងវិធានការឆ្លើយតបទាំង៧ នៃសេចក្តីថ្លែងការណ៍របស់ប្រមុខរដ្ឋនៃប្រទេសជាសមាជិកអាស៊ានរួមមាន៖ ១.ពង្រឹងប្រសិទ្ធភាពការអនុវត្តគោលនយោបាយនិងអភិបាលកិច្ច ២.លើកកម្ពស់យុត្តិធម៌ព្រហ្មទណ្ឌ ៣.លើកកម្ពស់វិធានការបង្ការ ទប់ស្កាត់ និងស្តារនីតិសម្បទាជនរងគ្រោះដោយអំពើកេងប្រវ័ញ្ចផ្លូវភេទតាមប្រព័ន្ធអនឡាញ ៤.ពង្រឹងសុវត្ថិភាពសហគមន៍ពីការរំលោភបំពាននិងកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ ៥.ពង្រឹងលក្ខន្តិកៈ សម្រាប់ការផ្តល់សេវាអ៊ីនធឺណិត ៦.បង្កើនការផ្សព្វផ្សាយនិងការយល់ដឹងត្រឹមត្រូវអំពីបញ្ហាការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ។ សកម្មភាពបង្ការទប់ស្កាត់និងឆ្លើយតបដែលបង្ហាញនៅក្នុងគោលដៅនីមួយៗនៃផែនការសកម្មភាព នឹងត្រូវអនុវត្តដោយក្រសួង ស្ថានប័នពាក់ព័ន្ធនៅថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ រួមទាំងដៃគូអភិវឌ្ឍន៍ ប្រកបដោយការទទួលខុសត្រូវខ្ពស់។

ក្នុងនាមក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ ខ្ញុំមានកិត្តិយស និងមោទនភាពដែលបានសម្របសម្រួលរៀបចំផែនការសកម្មភាពដើម្បីបង្ការ ទប់ស្កាត់ និងឆ្លើយតបការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ ឆ្នាំ២០២១-២០២៥ និងបន្តសហការគ្នាដើម្បីអនុវត្តផែនការសកម្មភាពនេះប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផល គឺតម្រូវឱ្យមានការចូលរួមពីក្រសួង ស្ថាប័នពាក់ព័ន្ធ អង្គការមិនមែនរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ ក្មួយៗកុមារ និងក្រុមគ្រួសារ គឺមានសារៈសំខាន់ណាស់។ ខ្ញុំសូមថ្លែងអំណរគុណចំពោះក្រសួង ស្ថានប័នពាក់ព័ន្ធ អង្គការមិនមែនរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ និងអ្នកពាក់ព័ន្ធទាំងឡាយ ដែលតែងតែផ្តល់ការគាំទ្រជាបន្តបន្ទាប់។

ថ្ងៃទីព្រហស្បតិ៍ ៧រោច ខែ មាឃ ឆ្នាំ ជូត ព.ស ២៥៦៤

រាជធានីភ្នំពេញ, ថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០២១

**ប្រធានក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ**

**វង សូត**

# មាតិកា


**អារម្ភកថា** ..... i
**អក្សរកាត់** ..... iv
**និយមន័យ** ..... v
**១. សេចក្តីផ្តើម** ..... ១
**១.១.សាវតារ និងបរិបទ** ..... ១
១.១.១.សិទ្ធិមូលដ្ឋានទាំង៤របស់កុមារ ..... ២
១.១.២.សេចក្តីថ្លែងការណ៍សកម្មភាពសកល(WePROTECT) ឆ្នាំ២០១៥ ..... ៤
១.១.៣.សេចក្តីថ្លែងការណ៍ប្រមុខរដ្ឋនៃប្រទេសជាសមាជិកអាស៊ានឆ្នាំ២០១៩ ..... ៤
១.១.៤.ផែនការសកម្មភាពទប់ស្កាត់ និងឆ្លើយតបចំពោះអំពើហិង្សាលើកុមារ ២០១៧-២០២១ ..... ៥
១.១.៥.របាយការណ៍វិភាគស្ថានភាពដំបូងស្តីពី(OCSE)នៅកម្ពុជា ..... ៥
**១.២.ស្ថានភាពការកេងប្រវ័ញ្ចផ្លូវភេទតាមប្រព័ន្ធអនឡាញ** ..... ៧
**១.៣.ទំនាក់ទំនងរវាងផែនការសកម្មភាព និងក្របខ័ណ្ឌគតិយុត្តពាក់ព័ន្ធ** ..... ១០
**១.៤.ដំណើរការរៀបចំផែនការសកម្មភាព** ..... ១០
**២. វឌ្ឍនភាព និងបញ្ហាប្រឈម** ..... ១១
**២.១.វឌ្ឍនភាព** ..... ១១
**២.២.បញ្ហាប្រឈម** ..... ១២
**៣. គោលដៅយុទ្ធសាស្ត្រ និងលទ្ធផលរំពឹងទុក** ..... ១៣
គោលដៅយុទ្ធសាស្ត្រទី១៖ពង្រឹងប្រសិទ្ធភាពការអនុវត្តគោលនយោបាយ និងអភិបាលកិច្ច ..... ១៣
គោលដៅយុទ្ធសាស្ត្រទី២៖លើកកម្ពស់យុត្តិធម៌ព្រហ្មទណ្ឌ ..... ១៥
គោលដៅយុទ្ធសាស្ត្រទី៣៖លើកកម្ពស់វិធានការបង្ការ ទប់ស្កាត់ និងស្តារនីតិសម្បទាជនរងគ្រោះពី(OCSE) ..... ១៦
គោលដៅយុទ្ធសាស្ត្រទី៤៖ពង្រឹងសុវត្ថិភាពសហគមន៍ពី(OCSE) ..... ១៨
គោលដៅយុទ្ធសាស្ត្រទី៥៖ពង្រឹងលក្ខន្តិកសម្រាប់ការផ្តល់សេវាអ៊ីនធឺណិត ..... ១៩
គោលដៅយុទ្ធសាស្ត្រទី៦៖បង្កើនការផ្សព្វផ្សាយ និងការយល់ដឹងត្រឹមត្រូវអំពីបញ្ហា(OCSE) ..... ២១
**៤. តម្រូវការថវិកាសម្រាប់អនុវត្តផែនការសកម្មភាព** ..... ២២
**៥. ការពិនិត្យតាមដាន និងវាយតម្លៃ** ..... ២៣
**៦. សេចក្តីសន្និដ្ឋាន** ..... ២៣
**ឧបសម្ព័ន្ធ** ..... ២៤

## អក្សរកាត់

| | |
|---|---|
| APLE | អង្គការសកម្មភាពដើម្បីកុមារ |
| CNCC | ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ |
| TdH-NL | អង្គការដែនដីមនុស្ស-ហូឡង់ដ៍ |
| CSEA | ការរំលោភបំពាន និងការកេងប្រវ័ញ្ចផ្លូវភេទលើកុមារ |
| CSAM | រូបភាព-សម្ភាររំលោភបំពានផ្លូវភេទលើកុមារ |
| CSEM | សម្ភារពាក់ព័ន្ធនឹងកេងប្រវ័ញ្ចផ្លូវភេទលើកុមារ |
| IP | ពិធីសារអ៊ិនធឺណិត(អាសយដ្ឋាន IP) |
| ICT | បច្ចេកវិទ្យាទូរគមនាគមន៍ និងព័ត៌មាន |
| IWF | មូលនិធិឃ្លាំមើលតាមប្រព័ន្ធអ៊ិនធឺណិត |
| MNR | គំរូឆ្លើយតបថ្នាក់ជាតិ |
| NCCT | គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស |
| MoI | ក្រសួងមហាផ្ទៃ |
| HoH | ក្រសួងសុខាភិបាល |
| MoIn | ក្រសួងព័ត៌មាន |
| MoPTC | ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ |
| MoEYS | ក្រសួងអប់រំ យុវជន និងកីឡា |
| MoJ | ក្រសួងយុត្តិធម៌ |
| MoCFA | ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ |
| MoCR | ក្រសួងធម្មការនិងសាសនា |
| MoSVY | ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា |
| MoWA | ក្រសួងកិច្ចការនារី |
| NCMEC | មជ្ឈមណ្ឌលជាតិការពារកុមារបាត់ខ្លួន និងរងគ្រោះដោយការកេងប្រវ័ញ្ច |
| LGBT | អ្នកស្រឡាញ់ភេទដូចគ្នា និងអ្នកប្តូរភេទ |
| OCSE | ការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ |
| TRC | និយ័តករទូរគមនាគមន៍កម្ពុជា |

## និយមន័យ

**ការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ** (Online Child Sexual Exploitation_OCSE) សំដៅលើរាល់ទង្វើនៃការកេងប្រវ័ញ្ចផ្លូវភេទដែលអាចកើតឡើងចំពោះកុមារ តាមរយៈការប្រើប្រាស់ប្រព័ន្ធអនឡាញ។ រួមបញ្ចូលទាំងការប្រើប្រាស់បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន ជាមធ្យោបាយដើម្បីទទួលបានការកេងប្រវ័ញ្ចផ្លូវភេទលើកុមារ ឬបណ្ដាលឱ្យកុមារត្រូវបានគេកេងប្រវ័ញ្ចផ្លូវភេទ ឬក៏ជាមធ្យោបាយក្នុងការផលិត កាន់កាប់ ចែកចាយ ឬបញ្ជូននូវរូបភាព ឬសម្ភារដែលពាក់ព័ន្ធនឹងការកេងប្រវ័ញ្ចផ្លូវភេទលើកុមារ។[1]

**ការលួងលោមកុមារតាមប្រព័ន្ធអនឡាញ** (Online Grooming) សំដៅទៅលើជនខិលខូចដែលព្យាយាមទាក់ទងកុមារតាមប្រព័ន្ធអនឡាញ ដើម្បីកសាងទំនុកចិត្តក្នុងគោលបំណងកេងប្រវ័ញ្ចផ្លូវភេទពួកគេ។ ការលួងលោមទាំងនោះរួមមាន ការបង្ហាញនូវសម្ភារអាសអាភាសដូចជាតាមរយៈការផ្ញើនូវមាតិកា សារ វីដេអូ ឬរូបភាពបែបផ្លូវភេទទៅកាន់កុមារ។ វិធីទាំងនេះ អាចជួយឱ្យជនល្មើសផ្លូវភេទលើកុមារអាចបន្សាំកុមារទៅនឹងរឿងរ៉ាវផ្លូវភេទក្នុងគោលដៅបង្កើនឱកាសឱ្យកុមារបញ្ជូនសម្ភារផ្លូវភេទដោយខ្លួនឯងទៅឱ្យជនល្មើស។

**រូបភាព-សម្ភាររំលោភបំពានផ្លូវភេទលើកុមារ** (Child Sexual Abuse Material_CSAM) សំដៅលើសម្ភារដែលបង្ហាញពីកុមារក្នុងស្ថានភាពអាក្រាត ពិពណ៌នាដោយផ្ដោតលើកេរ្តិ៍ភេទរបស់កុមារ ឬសម្ភារដែលពណ៌នាអំពីកុមារនៅក្នុងស្ថានភាពបែបអាសអាភាស។ សម្ភារទាំងនោះរួមមាន រូបភាព វីដេអូ អត្ថបទ និងសារសម្លេង ដែលមានលក្ខណៈបែបអាសអាភាសជាដើម។

**ការផ្ញើសារបែបផ្លូវភេទ** (Sexting) គឺជាសកម្មភាពនៃការផ្ញើ ឬទទួលរូបភាពបែបផ្លូវភេទដែលបង្កើតឡើងដោយខ្លួនឯងទៅឱ្យអ្នកដទៃផ្សេងទៀត។ ពេលខ្លះ ការផ្ញើ ឬការបញ្ជូនរូបភាពផ្លូវភេទដែលបង្កើតឡើងដោយខ្លួនឯងត្រូវបានធ្វើឡើងដោយការស្ម័គ្រចិត្ត ឬធ្វើឡើងបន្ទាប់ពីទទួលរងការគំរាមកំហែង ការដាក់សម្ពាធ ការរៀបចំឡើង និង/ឬការបង្ខិតបង្ខំពីមនុស្សម្នាក់ទៀត។

**ការគំរាមបែបផ្លូវភេទ** (Sextortion) គឺជាទង្វើដែលជនល្មើសផ្លូវភេទលើកុមារប្រើប្រាស់សម្ភាររំលោភបំពានផ្លូវភេទដែលបានទទួលពីកុមារជាញឹកញាប់ តាមរយៈការផ្ញើ ឬការបញ្ជូនរូបភាពផ្លូវភេទដែលបង្កើតឡើងដោយខ្លួនឯងដើម្បីគំរាមកុមារឱ្យបញ្ជូនសម្ភារផ្លូវភេទបន្ថែមទៀតដល់ពួកគេ ដើម្បីជួបផ្ទាល់ក្នុងគោលបំណងផ្លូវភេទ ឬដើម្បីទទួលបាននូវផលប្រយោជន៍ផ្សេងទៀតដូចជា លុយកាក់ ឬការគ្រប់គ្រងលើកុមារជាដើម។

**ការផ្សាយផ្ទាល់អំពើរំលោភបំពានផ្លូវភេទលើកុមារ** (Live Online Child Sexual Abuse) សំដៅលើការផ្សាយផ្ទាល់នៃសកម្មភាពរំលោភបំពានផ្លូវភេទពាក់ព័ន្ធកុមារ ឬការឱ្យកុមារសម្ដែងបែបផ្លូវភេទនៅមុខកាមេរ៉ា (អាចក្នុងស្ថានភាពអាក្រាត ឬក្នុងស្ថានភាពផ្លូវភេទ) ពេលខ្លះ ជនល្មើសផ្លូវភេទលើកុមារអាចផ្ដល់ជាប្រាក់ដល់កុមារផ្ទាល់ អ្នកសម្របសម្រួល ឬអន្តរការីដើម្បីដោះដូរជាមួយនឹងសកម្មភាពនោះ។

**ការរំលោភបំពាន និងការកេងប្រវ័ញ្ចផ្លូវភេទលើកុមារ** (Child Sexual Exploition and Abuse_CSEA) គឺជាពាក្យបញ្ចូលសម្រាប់ទាំងការរំលោភបំពានផ្លូវភេទនិងការកេងប្រវ័ញ្ចដោយមនុស្សពេញវ័យ។ ការកេងប្រវ័ញ្ចផ្លូវភេទទាក់ទងនឹងការរួមភេទជាមួយកុមារជាថ្នូរនឹងសំណាងមួយចំនួនដែលអាចជារូបិយវត្ថុ ប៉ុន្តែកុមារអាចទទួលបាន

---

[1]ក្រុមការងារអន្តរទីភ្នាក់ងារស្ដីពីការកេងប្រវ័ញ្ចផ្លូវភេទកុមារ ឆ្នាំ២០១៦ "គោលការណ៍ណែនាំស្ដីពីវាក្យស័ព្ទសម្រាប់កិច្ចការពារកុមារពីការកេងប្រវ័ញ្ច ផ្លូវភេទនិងការរំលោភបំពានផ្លូវភេទ"ទាញយកពី ៖ http://luxembourgguidelines.org/.

តែអាហារ ឬកន្លែងគេង។ ការរំលោភបំពានផ្លូវភេទត្រូវបានគេយល់ថា ជាការទាក់ទងផ្លូវភេទជាមួយផ្នែកឯកជនរបស់កុមារដោយមាន ឬគ្មានការយល់ព្រមរបស់ពួកគេនិងដោយមាន ឬគ្មានប្រើកម្លាំងកាយ។ ការរំលោភបំពានមិនតម្រូវឱ្យមានជាតុនៃការផ្លាស់ប្តូរទេ ហើយអាចកើតឡើងតែចំពោះការពេញចិត្តខាងផ្លូវភេទរបស់មនុស្សដែលប្រព្រឹត្តអំពើនេះ។[2]

[2] ចំណុចនេះមានចែងក្នុងច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ និងក្រមព្រហ្មទណ្ឌ

# ១. សេចក្តីផ្តើម

## ១.១. សាវតារ និងបរិបទ

រាជរដ្ឋាភិបាលដឹកនាំដោយសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាបានបោះជំហានទៅមុខក្នុងការស្តារសង្គម និងសេដ្ឋកិច្ចឡើងវិញដែលក្នុងពីរទសវត្សរ៍ចុងក្រោយនេះ សម្រេចកំណើនសេដ្ឋកិច្ចជាបន្តបន្ទាប់ និងកំពុងសមាហរណកម្មខ្លួនចូលក្នុងតំបន់ និងពិភពលោក ដែលធ្វើឱ្យកម្ពុជាទទួលបានឱកាសជាច្រើនក្នុងការកសាង និងអភិវឌ្ឍប្រទេសជាតិ។ ស្របពេលជាមួយគ្នានេះ រាជរដ្ឋាភិបាលនីតិកាលទី៦នៃរដ្ឋសភា បានដាក់ចេញនូវយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ ដោយធ្វើការវិភាជន៍ធនធានបន្ថែមដល់វិស័យសុខាភិបាល អប់រំ សង្គមកិច្ច និងវិស័យផ្សេងៗទៀត សម្រាប់ជំរុញការអភិវឌ្ឍធនធានមនុស្ស រួមទាំងការអភិវឌ្ឍកុមារសំដៅសម្រេចឱ្យបាននូវគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ២០១៦-២០៣០ ទន្ទឹមនឹងនេះ កម្ពុជាបានត្រៀមខ្លួនជាស្រេចក្នុងការចូលរួមក្នុងបដិវត្តឧស្សាហកម្មទី៤ ដែលផ្តោតជាពិសេសលើវិស័យបច្ចេកវិទ្យា ដែលពិភពលោកកំពុងប្រើប្រាស់សម្រាប់វិស័យនយោបាយ សេដ្ឋកិច្ច និងសង្គមកិច្ចបានយ៉ាងមានប្រសិទ្ធភាព។ ការរីកចម្រើនផ្នែកបច្ចេកវិទ្យាព័ត៌មានបានជំរុញដល់ការរីកលូតលាស់ការងារ នយោបាយ សេដ្ឋកិច្ច និងសង្គមកិច្ច ដែលធ្វើឱ្យកម្ពុជាមានទំនាក់ទំនងជាមួយបណ្តាប្រទេសក្នុងតំបន់ និងពិភពលោកថែមទៀតផង។

ការរីកចម្រើនផ្នែកបច្ចេកវិទ្យាព័ត៌មានបង្កើតឱ្យមានការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ ដែលជាទម្រង់ថ្មីមួយកំពុងរាលដាលនៅលើពិភពលោក រួមទាំងកម្ពុជាផងដែរ។ ដោយមើលឃើញបញ្ហាប្រឈម និងផលប៉ះពាល់ពីការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញនេះ រាជរដ្ឋាភិបាលកម្ពុជាបានសម្រេចចូលជារដ្ឋភាគីហត្ថលេខីនៃសេចក្តីថ្លែងការណ៍សកម្មភាពសកល (WePROTECT) ដែលបានចុះហត្ថលេខានៅឯកិច្ចប្រជុំកំពូលជាសកលនៅទីក្រុងអាប៊ុយដាប៊ីកាលពីឆ្នាំ២០១៥ ដែលមានក្រសួងមហាផ្ទៃជាអ្នកសម្របសម្រួល។ សេចក្តីថ្លែងការណ៍សកម្មភាពសកលនេះ បានបង្កើតយន្តការឆ្លើយតបថ្នាក់ជាតិគំរូ (MNR) ដែលសង្កត់ធ្ងន់លើសារសំខាន់នៃការចូលរួមរបស់អ្នកពាក់ព័ន្ធនានា និងកំណត់នូវឧស្សាហកម្មពាក់ព័ន្ធធំៗនៅក្នុងកិច្ចការពារកុមារតាមប្រព័ន្ធអនឡាញ និងបានរៀបចំផែនការសកម្មភាពទប់ស្កាត់ និងឆ្លើយតបចំពោះអំពើហិង្សាលើកុមារ ឆ្នាំ២០១៧-២០២១ ដែលបានលើកទឹកចិត្តឱ្យមានសកម្មភាពទប់ស្កាត់អំពើហិង្សា និងកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញផងដែរ។ កម្ពុជាចូលជាសមាជិកនៃប្រទេសភាពជាដៃគូសកលដើម្បីលុបបំបាត់អំពើហិង្សាលើកុមារ (Pathfinding Country) នៅថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១៩ បន្ថែមពីនេះប្រមុខរាជរដ្ឋាភិបាលកម្ពុជាបានចូលរួមអនុម័តលើសេចក្តីថ្លែងការណ៍នាកិច្ចប្រជុំកំពូលថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១៩ ក្នុងគោលបំណងអំពាវនាវឱ្យរដ្ឋជាសមាជិកអាស៊ានទាំងអស់ប្រើប្រាស់បទដ្ឋានកម្រិតខ្ពស់ដើម្បីការពារកុមារទាំងអស់នៅក្នុងអាស៊ានពីការកេងប្រវ័ញ្ច និងរំលោភបំពានផ្លូវភេទតាមប្រព័ន្ធអនឡាញដោយបានដាក់ចេញវិធានការចំនួន៧ ដើម្បីបង្ការ ទប់ស្កាត់ និងឆ្លើយតប។

ដើម្បីស្វែងយល់ពីស្ថានភាពបញ្ហាកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិកម្ពុជា (ក.ជ.ក) សហការជាមួយអង្គការដៃគូធ្វើការវិភាគស្ថានភាពដំបូងដើម្បីប៉ាន់ប្រមាណផលប៉ះពាល់លើការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញនៅកម្ពុជាតាមនីតិវិធីមួយចំនួន រួមមាន៖ ប៉ាន់ប្រមាណទីកន្លែង និងវិធីសាស្ត្រ ដែលជាកត្តាជំរុញកុមារឱ្យស្ថិតក្នុងស្ថានភាពងាយរងគ្រោះ ព្រមទាំងកំណត់នូវសមត្ថភាព និងភាពខ្វះចន្លោះនៃគោលនយោបាយជាតិ លិខិតបទដ្ឋានគតិយុត្ត យុត្តិធម៌ព្រហ្មទណ្ឌ សេវាសង្គម និងវិស័យឯកជន។ ការប៉ាន់ប្រមាណនេះ ធ្វើឡើងក្នុងគោលបំណងកំណត់នូវ "អនុសាសន៍ដែលអាចធ្វើបានដោយផ្អែកលើភស្តុតាង" ដើម្បីឆ្លើយតបទៅនឹងការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ នៅក្នុងបរិបទនៃប្រទេសកម្ពុជា ដែល

អនុលោមទៅតាមគំរូនៃការឆ្លើយតបថ្នាក់ជាតិ (MNR) នៃ WePROTECT ដោយរៀនពីការអនុវត្តល្អនៅកម្រិតជាតិ និងអន្តរជាតិ និងបានចេញផ្សាយជាផ្លូវការនូវរបាយការណ៍វិភាគស្ថានភាពដំបូងស្តីពីការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញនាថ្ងៃទី១០ ខែមករា ឆ្នាំ២០២០។

### ១.១.១.សិទ្ធិមូលដ្ឋានទាំង៤របស់កុមារ

អនុសញ្ញាស្តីពីសិទ្ធិកុមារ[3]ទទួលស្គាល់ថាកុមារមានសិទ្ធិរបស់គេផ្ទាល់ ហើយពួកគេគឺជាម្ចាស់សិទ្ធិ។ កុមារអាចទាមទារសិទ្ធិរបស់ខ្លួនពីអ្នកមានភារកិច្ចនានា ដូចជាឪពុកម្តាយ និងរដ្ឋ ជាពិសេសមន្ត្រីមានសមត្ថកិច្ចដែលមានភារកិច្ចការពារនិងលើកកម្ពស់សិទ្ធិកុមារ ក៏ដូចសិទ្ធិមនុស្សមិនអាចបំបែកពីគ្នាបានទេ គឺមានទំនាក់ទំនងគ្នា ហើយពុំមានសិទ្ធិណាមួយសំខាន់ជាងសិទ្ធិណាមួយឡើយ។ កុមារត្រូវបានចាត់ទុកជាបុគ្គលដែលកើតមកភ្ជាប់ជាមួយសិទ្ធិមនុស្ស និងសេចក្តីថ្លៃថ្នូរស្មើៗគ្នាក្នុងនាមជាមនុស្ស។ អនុសញ្ញាស្តីពីសិទ្ធិកុមារ មានសិទ្ធិជាមូលដ្ឋានសំខាន់ៗចំនួន ៤ ដូចខាងក្រោម៖

**សិទ្ធិរស់រានមានជីវិត៖** កុមារត្រូវមានជីវិតរស់នៅ មានសុវត្ថិភាព និងមានអ្វីៗចាំបាច់សម្រាប់រស់នៅ ដូចជាចំណីអាហារមានជីវជាតិ មានឈ្មោះ និងមានសញ្ជាតិ ការបង្ការនិងព្យាបាលសុខភាព សម្លៀកបំពាក់ ជម្រកស្នាក់នៅសមរម្យ និងមានជីវភាពគ្រប់គ្រាន់ ព្រមទាំងទទួលបានការថ្នាក់ថ្នមអំពីឪពុកម្តាយ អាណាព្យាបាល និងសង្គម។ កុមារមិនត្រូវទទួលរងការវាយធ្វើបាបឬទារុណកម្មឡើយ។ ឪពុកម្តាយត្រូវយល់ផងដែរថា សហគមន៍មូលដ្ឋាន អាជ្ញាធរមូលដ្ឋាន អាជ្ញាធរជាតិ និងសហគមន៍អន្តរជាតិ ក៏មានចំណែកទទួលខុសត្រូវចំពោះសិទ្ធិរស់រានរបស់កុមារផងដែរ មានន័យថា ជីវិតកូនរបស់អ្នកស្ថិតនៅក្រោមកិច្ចការពាររបស់សហគមន៍មូលដ្ឋាន អាជ្ញាធរមូលដ្ឋាន អាជ្ញាធរអន្តរជាតិ និងសហគមន៍អន្តរជាតិ។ ឪពុកម្តាយ ឬអាណាព្យាបាល អាចរងការប្តឹងពីសហគមន៍ អាជ្ញាធរមូលដ្ឋាន និងអ្នកពាក់ព័ន្ធចំពោះអំពើដែលឪពុកម្តាយបានរំលោភលើសិទ្ធិរស់រានរបស់កុមារ។ ឪពុកម្តាយអាចប្តឹងតវ៉ាប្រឆាំងនឹងអាជ្ញាធរមានសមត្ថកិច្ចអំពីការមិនយកចិត្តទុកដាក់ ឬមិនផ្តល់កិច្ចការពារ ឬបានរំលោភលើសិទ្ធិរស់រានរបស់កុមារ។[4]

រូបភាពទី១៖ សិទ្ធិរស់រានមានជីវិត




១.១.ការទទួលបានចំណីអាហារ ១.២.ការមានជម្រកសមរម្យ ១.៣.ការថែទាំសុខភាព ១.៤.ការបានឈ្មោះ និងសញ្ជាតិ

**សិទ្ធិក្នុងការអភិវឌ្ឍ៖** កុមារត្រូវទទួលបាននូវការសិក្សារៀនសូត្រគ្រប់ប្រភេទ គឺការសិក្សានៅសាលារៀន និងនៅតាមផ្ទះ ឬសហគមន៍ ដូចជាទទួលការអប់រំ និងផ្តល់ដំបូន្មានល្អៗស្តីពីការរស់នៅ ការលេងកំសាន្តនិងលំហែ ការសម្តែងសិល្បៈវប្បធម៌ ស្រឡាញ់ថ្នាក់ថ្នម ការបណ្តុះបណ្តាលវិជ្ជាជីវៈ និងការថែបំប៉នសុខភាព។[5]

---

[3] កម្ពុជាបានផ្តល់សច្ចាប័នលើអនុសញ្ញាស្តីពីសិទ្ធិកុមារនៅថ្ងៃទី១៥ ខែតុលា ឆ្នាំ១៩៩២

[4] មានចែងនៅមាត្រា ៦, ៧, ៨, ៩, ១៩, ២០, ២១, ២៣, ២៤, ២៦, ២៧, ៣០, ៣២, ៣៣, ៣៤, ៣៥, ៣៨ នៃអនុសញ្ញាស្តីពីសិទ្ធិកុមារ

[5] មានចែងនៅមាត្រា ៥, ៦, ៧, ៩, ១០, ១១, ១២, ១៣, ១៤, ១៥, ១៧, ២៤, ២៨, ២៩, ៣១ នៃអនុសញ្ញាស្តីពីសិទ្ធិកុមារ

រូបភាពទី២៖ សិទ្ធិក្នុងការអភិវឌ្ឍ

|  |  |  |  |
|---|---|---|---|
| ២.១.ការទទួលបានការអប់រំ | ២.២.ការលេងកំសាន្ត និងលំហែ | ២.៣.ការសម្តែងសិល្បៈ វប្បធម៌ | ២.៤.ការស្រឡាញ់ថ្នាក់ថ្នម |

**សិទ្ធិទទួលបាននូវការការពារ៖** ឪពុកម្តាយត្រូវមើលថែរក្សានិងប្រៀនប្រដៅកុមារ ហើយអាជ្ញាធរគ្រប់លំដាប់ថ្នាក់ ត្រូវចាត់វិធានការជួយកុមារឱ្យរួចផុតពីគ្រោះមហន្តរាយនានាដូចជា គ្រឿងញៀន ល្បែងអបាយមុខ អំពើអនាចារ ការរើសអើង ការសេពកាមគុណលើកុមារ ការធ្វើអាជីវកម្មលើកុមារ ការលក់ដូរកុមារ និងអំពើដទៃៗទៀតដែលប៉ះពាល់ដល់ផលប្រយោជន៍ធំបំផុតរបស់កុមារ។ ឪពុកម្តាយត្រូវការពារកូនរបស់ខ្លួន និងចូលរួមចំណែកការពារកុមារពីការរំលោភទាំងឡាយដែលអាចកើតមានពីអាជ្ញាធរមូលដ្ឋានឬអាជ្ញាធរជាតិ។ គេអាចបង្កើតសមាគមមាតាបិតានៅក្នុងសហគមន៍មូលដ្ឋានក្នុងគោលបំណងការពារសិទ្ធិកុមារ។ អាជ្ញាធរមូលដ្ឋានក៏មានភារកិច្ចការពារកុមារពីការរំលោភនានាដែលអាចប្រព្រឹត្តដោយឪពុកម្តាយ ឬអាណាព្យាបាលរបស់កុមារ និងអ្នកមានអំណាចលើកុមារផ្សេងៗទៀតផងដែរ។[6]

រូបភាពទី៣៖ សិទ្ធិទទួលបាននូវការការពារ

|  |  |  |  |
|---|---|---|---|
| ៣.១.ការការពារពីការកេងប្រវ័ញ្ចផ្លូវភេទ | ៣.២.ការការពារអំពីការប្រើប្រាស់គ្រឿងញៀន | ៣.៣.ការការពារអំពីការធ្វើពលកម្មធ្ងន់ធ្ងរ | ៣.៤.ការការពារអំពីអំពើហិង្សាគ្រប់ប្រភេទ |

**សិទ្ធិក្នុងការចូលរួម៖** កុមារមានសិទ្ធិចូលរួមបញ្ចេញមតិយោបល់លើបញ្ហា ឬសកម្មភាពដែលមានឥទ្ធិពលដល់ដំណើរជីវិតរបស់ពួកគេ ចូលរួមសកម្មភាពក្នុងសមាគម និងការប្រជុំនានា និងចូលរួមទទួល និងផ្សព្វផ្សាយព័ត៌មាន អានសៀវភៅ កាសែត ទស្សនាវដ្តី ស្តាប់វិទ្យុ មើលទូរទស្សន៍ ដើម្បីពង្រីកការយល់ដឹង និងចេះប្រើវិចារណញ្ញាណរិះគិតចំពោះព្រឹត្តិការណ៍ផ្សេងៗ។[7]

រូបភាពទី៤៖ សិទ្ធិក្នុងការចូលរួម

|  |  |  |  |
|---|---|---|---|
| ៤.១.ការបញ្ចេញមតិយោបល់ | ៤.២.ការបង្កើតក្លឹមកុមារ និងសមាគម | ៤.៣.ការចូលរួមផ្សព្វផ្សាយ និងទទួលព័ត៌មាន | ៤.៤.ការយល់ដឹងពី អ.ស.ក |

៨៩-១

[6] មានចែងនៅមាត្រា ២, ៧, ១១, ១៦, ១៩, ២០, ២២, ២៣, ២៥, ៣០, ៣២, ៣៣, ៣៤ ៣៥, ៣៦, ៣៦, ៣៨, ៣៩, ៤០ នៃអនុសញ្ញា CRC

[7] មានចែងនៅមាត្រា ១២, ១៣, ១៥, ១៧, ៤២ នៃអនុសញ្ញាស្តីពីសិទ្ធិកុមារ

### ១.១.២. សេចក្តីថ្លែងការណ៍សកម្មភាពសកល (WePROTECT) ឆ្នាំ២០១៥

សេចក្តីថ្លែងការណ៍សកម្មភាពសកល (WePROTECT) ឆ្នាំ២០១៥ បានបង្កើតយន្តការឆ្លើយតបថ្នាក់ជាតិគំរូ (MNR) ដែលសង្កត់ធ្ងន់លើសារសំខាន់នៃការចូលរួមរបស់អ្នកពាក់ព័ន្ធនានា និងកំណត់នូវឧស្សាហកម្មពាក់ព័ន្ធធំៗ នៅក្នុងកិច្ចការពារកុមារតាមប្រព័ន្ធអនឡាញ។ យន្តការឆ្លើយតបថ្នាក់ជាតិគំរូ (MNR) មាន៖ ១.គោលនយោបាយនិងអភិបាលកិច្ច (ការប្តេជ្ញាចិត្តខ្ពស់ក្នុងកិច្ចបង្ការនិងការឆ្លើយតប) ២.យុត្តិធម៌ព្រហ្មទណ្ឌ (ការស៊ើបអង្កេតកាត់ទោសដោយជោគជ័យនិងប្រសិទ្ធភាព និងការគ្រប់គ្រងជនល្មើស) ៣.សេវាជនរងគ្រោះ (វិធានការរក្សាសុវត្ថិភាពសម្រាប់កុមារនិងយុវជន) ៤.សង្គម (ការកេងប្រវ័ញ្ចនិងរំលោភបំពានផ្លូវភេទត្រូវបានបង្ការ) ៥.ឧស្សាហកម្ម (ផ្នែកឧស្សាហ៍កម្មចូលរួមក្នុងការបង្កើតដំណោះស្រាយបង្ការ និងលុបបំបាត់ការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ) និង ៦.ប្រព័ន្ធផ្សព្វផ្សាយ និងទំនាក់ទំនង (ចំណេះដឹងត្រូវបានលើកកម្ពស់សម្រាប់សាធារណៈជន អ្នកជំនាញ និងអ្នកធ្វើច្បាប់ និងគោលនយោបាយ)។

រូបភាពទី៥៖ការឆ្លើយតបថ្នាក់ជាតិគំរូ (Model National Respond_MNR)




### ១.១.៣. សេចក្តីថ្លែងការណ៍ប្រមុខរដ្ឋនៃប្រទេសជាសមាជិកអាស៊ានឆ្នាំ២០១៩

ប្រមុខរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងប្រមុខដឹកនាំរដ្ឋជាសមាជិកនៃប្រទេសអាស៊ានទាំងអស់ បានអនុម័តលើសេចក្តីថ្លែងការណ៍ស្តីពីការការពារកុមារពីគ្រប់ទម្រង់នៃអំពើកេងប្រវ័ញ្ច និងរំលោភបំពានផ្លូវភេទ នៅកិច្ចប្រជុំកំពូលថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១៩ ក្នុងគោលបំណងអំពាវនាវឱ្យរដ្ឋជាសមាជិកអាស៊ានទាំងអស់ប្រើប្រាស់បទដ្ឋានកម្រិតខ្ពស់ ដើម្បីការពារកុមារទាំងអស់នៅក្នុងអាស៊ានពីការកេងប្រវ័ញ្ច និងរំលោភបំពានផ្លូវភេទតាមអនឡាញ ដោយប្តេជ្ញាតាមរយៈវិធានការ ដូចជា៖ ១.ជំរុញ បង្កើត និងអនុវត្តក្របខណ្ឌច្បាប់ជាតិ ២.បង្កើនសមត្ថភាពរបស់មន្ត្រីអនុវត្តច្បាប់និងតុលាការ ៣.លើកទឹកចិត្តឱ្យបង្កើតអង្គភាពជំនាញមួយទទួលខុសត្រូវដឹកនាំ គាំទ្រនិងសម្របសម្រួលការស៊ើបអង្កេត ៤.បង្កើនប្រសិទ្ធភាពនៃសេវាគាំទ្រនិងកិច្ចការពារកុមារ ៥.ពង្រឹងការប្រមូលទិន្នន័យ តាមដាន រាយការណ៍ បញ្ជូន និងប្រតិបត្តិការប្រព័ន្ធរាយការណ៍ពិសេស(Hotline) ៦.ជំរុញកម្មវិធីអប់រំថ្នាក់ជាតិ និងកម្មវិធីសិក្សាតាមសាលារៀន ដើម្បីលើកកម្ពស់ការយល់ដឹង និងពង្រឹងអំណាចកុមារ យុវជន ឪពុកម្តាយ និងសហគមន៍ និង ៧.កៀគរ និងបង្កើនការចូលរួមរបស់វិស័យឯកជន និងអ្នកពាក់ព័ន្ធដទៃទៀត ក្នុងការឆ្លើយតប(ធនធាន ការគោរពច្បាប់ និងពង្រឹងវិធានការរាយការណ៍ ស្វែងរក និងដកហូតរូបភាពខុសច្បាប់)។

### ១.១.៤. ផែនការសកម្មភាពទប់ស្កាត់ និងឆ្លើយតបចំពោះអំពើហិង្សាលើកុមារ ២០១៧-២០២១

ផែនការសកម្មភាពទប់ស្កាត់ និងឆ្លើយតបចំពោះអំពើហិង្សាលើកុមារ ២០១៧-២០២១ បានរំលេចពីអំពើកេងប្រវ័ញ្ចផ្លូវភេទកុមារតាមប្រព័ន្ធអនឡាញ(៣.២.៨)ដោយបានបញ្ជាក់ថា មិនទាន់មានការស្រាវជ្រាវណាមួយអំពីប្រេវ៉ាឡង់នៃការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញនៅកម្ពុជានៅឡើយទេ ប៉ុន្តែមន្ត្រីអនុវត្តច្បាប់និងអ្នកផ្តល់សេវាបានរាយការណ៍ឱ្យដឹងអំពីកំណើននៃការផលិត កាន់កាប់ និងចែកចាយតាមប្រព័ន្ធព័ត៌មានសង្គម និងតាមអ៊ីនធឺណិតនូវសម្ភារ និងរូបភាពស្តីពីអំពើរំលោភបំពានកុមារ ការល្បួងលោមកុមារតាមប្រព័ន្ធព័ត៌មានសង្គមក្នុងគោលបំណងកេងប្រវ័ញ្ចផ្លូវភេទ និងការផ្សាយផ្ទាល់ពីសកម្មភាពរំលោភបំពាន និងកេងប្រវ័ញ្ចកុមារតាមអ៊ីនធឺណិត។ មានភស្តុតាងជាច្រើនបានឱ្យដឹងថា អំពើកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ បណ្តាលឱ្យមានគ្រោះថ្នាក់យ៉ាងធ្ងន់ធ្ងរចំពោះជនរងគ្រោះ ដូចជា ភាពអាម៉ាស់យូរអង្វែង និងគ្មានអំណាចក្នុងខ្លួន ខណៈពេលដែលពួកគេចម្រើនវ័យឡើង[8]។ នៅក្នុងផែនការនេះតម្រូវឱ្យប្រមូលភស្តុតាង ដើម្បីធ្វើការប៉ាន់ប្រមាណឱ្យបានច្បាស់លាស់អំពីវិសាលភាព និងលក្ខណៈជាក់លាក់នៃអំពើកេងប្រវ័ញ្ចផ្លូវភេទកុមារតាមប្រព័ន្ធអនឡាញនៅកម្ពុជា។

### ១.១.៥. របាយការណ៍វិភាគស្ថានភាពដំបូងស្តីពីការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ

របាយការណ៍វិភាគស្ថានភាពដំបូងស្តីពីការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ កាលពីថ្ងៃទី១០ ខែមករា ឆ្នាំ២០២០ បានរកឃើញថាការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ គឺជាទម្រង់នៃការរំលោភបំពាន និងកេងប្រវ័ញ្ចផ្លូវភេទលើកុមារដែលកំពុងរាលដាល និងបង្កឡើងតាមរយៈប្រព័ន្ធអនឡាញ ការប្រើប្រាស់គេហទំព័រ បណ្តាញទំនាក់ទំនងសង្គម និងកម្មវិធីទូរស័ព្ទផ្សេងៗ។ ក្នុងនោះរួមមានការផលិតសម្ភាររំលោភបំពានផ្លូវភេទលើកុមារ (CSAM) អំពើល្បួងលោមតាមប្រព័ន្ធអនឡាញ (Online Grooming) អំពើផ្ញើសារបែបរំលោភបំពានផ្លូវភេទ (Sexting) អំពើគំរាមខាងផ្លូវភេទ (Sextortion) និងអំពើផ្សាយបន្តផ្ទាល់ការរំលោភបំពានផ្លូវភេទលើកុមារ(Live Online Child Sexual Abuse)។ តម្លៃសមរម្យនៃសេវាអ៊ិនធឺណិត កុំព្យូទ័រផ្ទាល់ខ្លួន និងទូរស័ព្ទដៃវៃឆ្លាត កំពុងរីកដុះដាលយ៉ាងឆាប់រហ័សនៅក្នុងសហគមន៍ដែលងាយរងគ្រោះនៅកម្ពុជា ហើយការភ្ជាប់អ៊ិនធឺណិតបណ្តាញទំនាក់ទំនងសង្គម និងការប្រើប្រាស់បច្ចេកវិទ្យា បានពង្រីកខ្លួនយ៉ាងខ្លាំងនៅក្នុងអំឡុងពេលប៉ុន្មានឆ្នាំនេះ សម្រួលឱ្យប្រជាជនកម្ពុជាជាងពាក់កណ្តាល នៃប្រជាជនសរុបមានទូរស័ព្ទដៃវៃឆ្លាតយ៉ាងតិចបំផុតម្នាក់១គ្រឿង (កើនឡើង២១ភាគរយ ធៀបនឹងឆ្នាំ២០១៥) និងចំនួន៤៨ភាគរយកំពុងប្រើប្រាស់ Facebook[9]។ ស្របពេលដែលសេវា និងឧបករណ៍ភ្ជាប់អ៊ិនធឺណិតទំនើប ហើយមានតម្លៃកាន់តែសមរម្យ ការប្រើប្រាស់មានការកើនឡើងគ្រប់ទីកន្លែងរួមទាំងនៅតាមសហគមន៍ដែលមានចំណូលទាប ដែលបង្កជាសក្តានុពលប្រកបដោយហានិភ័យខ្ពស់គួរឱ្យកត់សម្គាល់ចំពោះកុមារ និងយុវជនដែលទំនងជាអ្នកជំនាញក្នុងការប្រើប្រាស់អ៊ិនធឺណិតយ៉ាងសកម្មក្នុងបណ្តាញទំនាក់ទំនងសង្គម។ បច្ចុប្បន្នមានការយល់ដឹងតិចតួចនៅកម្ពុជាអំពីវត្តមាន និងទំហំនៃការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ[10] ហើយការយល់ដឹងរបស់សហគមន៍នៅមានកម្រិតទាប[11]។

ឧបសគ្គសំខាន់ៗក្នុងកិច្ចការពារកុមារពីការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ(OCSE) ដោយសារបញ្ហាមួយចំនួនរួមមាន៖ ១.កង្វះចំណេះដឹងអំពីឧបករណ៍(ICT)និងនិន្នាការនៃបច្ចេកវិទ្យា ២.កង្វះធនធាននៅ

[8] Ministry of Women's Affairs. (2014). Violence Against Women and Girls. Policy Brief 7. Received from: http://doi.org/10.1017/CBO9781107415324.004

[9] UNICEF 2016

[10] អង្គការសកម្មភាពដើម្បីកុមារ Action Pour Les Enfants [APLE] 2016

[11] ក្រសួងកិច្ចការនារី ២០១៤

សហគមន៍មូលដ្ឋាន ៣.កង្វះកិច្ចសហការជាមួយអ្នកមានជំនាញឯកទេស និងធនធានជាតិ ៤.ភាពពឹងផ្អែកជ្រុលលើវិធីសាស្ត្រស៊ើបអង្កេតផ្ទាល់បែបប្រពៃណី ៥.កង្វះអភិក្រមដែលគិតគូរអំពីជនរងគ្រោះ។ ដើម្បីដោះស្រាយបញ្ហាលើការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ ត្រូវមានលក្ខណៈគ្រប់ជ្រុងជ្រោយឆ្លើយតបចំពោះសមត្ថភាពនានាដែលត្រូវបានកំណត់នៅក្នុងក្របខណ្ឌគំរូនៃការឆ្លើយតបថ្នាក់ជាតិរបស់សេចក្តីថ្លែងការណ៍សកម្មភាពសកល (WePROTECT)ដែលបានចុះហត្ថលេខាដោយតំណាងរាជរដ្ឋាភិបាលកម្ពុជា នៅឯកិច្ចប្រជុំកំពូលជាសកលនៅទីក្រុងអាប៊ុយដាប៊ីកាលពីឆ្នាំ២០១៥។ ការឆ្លើយតបប្រកបដោយប្រសិទ្ធភាពចំពោះការកេងប្រវ័ញ្ចផ្លូវភេទលើកុមារនៅកម្ពុជា ត្រូវតែប្រមូលផ្តុំអ្នកពាក់ព័ន្ធជាច្រើនអង្គភាពអន្តរវិជ្ជាជីវៈ និងពហុវិស័យនៃស្ថាប័នទាំងអស់ដែលមានការទទួលខុសត្រូវចំពោះកិច្ចការពារកុមារនៅក្នុងបរិយាកាសអ៊ិនធឺណិត រួមទាំងសង្គមស៊ីវិល និងឧស្សាហកម្មឯកជនដែលគួរតែដឹកនាំសម្របសម្រួលដោយរដ្ឋាភិបាល។ របាយការណ៍វិភាគស្ថានភាពជំបូងស្តីពីការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ បានផ្តល់អនុសាសន៍មួយចំនួន ដើម្បីជាកាលានុវត្តភាពសម្រាប់អភិវឌ្ឍន៍ផែនការសកម្មភាព ដើម្បីបង្ការ ទប់ស្កាត់ និងឆ្លើយតបការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ រួមមាន៖

**ក.គោលនយោបាយ និងអភិបាលកិច្ច៖** គួរពិនិត្យ និងកែសម្រួលសេចក្តីព្រាងច្បាប់ស្តីពីបទល្មើសបច្ចេកវិទ្យាព័ត៌មាន ដោយកំណត់និយមន័យ និងបន្ថែមទោសប្បញ្ញត្តិពាក់ព័ន្ធការរំលោភបំពាន និងកេងប្រវ័ញ្ចផ្លូវភេទលើគ្រប់រូបភាព(CSAM) ដោយរាប់បញ្ចូលទាំងការលួងលោមតាមប្រព័ន្ធអនឡាញជាបទល្មើស។ គួរជំរុញការអនុម័តសេចក្តីព្រាងច្បាប់នេះឱ្យបានឆាប់រហ័ស។ ផ្អែកលើច្បាប់កម្ពុជាពាក់ព័ន្ធគួរកំណត់គោលការណ៍ណែនាំនិងកំណត់ស្តង់ដារដែលអាចរក្សាកំណត់ត្រាទិន្នន័យ IP (IP Assignment Log Preservation) តម្រូវឱ្យក្រុមហ៊ុនផ្តល់សេវាអ៊ិនធឺណិតទាំងអស់បង្កើតគោលនយោបាយការពារកុមារឆ្លើយតបឱ្យបានឆាប់រហ័ស និងការទទួលខុសត្រូវចំពោះមាតិកា (CSAM) នៅក្នុងសេវ៉ូបករណ៍ (servers) របស់ក្រុមហ៊ុន។ គួរបង្កើតយន្តការមួយ(ជាគណៈកម្មការឬក្រុមការងារ) ដោយមានការចូលរួមពីក្រសួងមហាផ្ទៃ ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ក្រសួងយុត្តិធម៌ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងព័ត៌មាន និងក្រសួងកិច្ចការនារី ដែលធ្វើការដាក់លាក់លើ(OCSE) ក្នុងការដោះស្រាយបានទាន់ពេលវេលា។ គួរធ្វើជាករណីសិក្សាទៅក្រៅប្រទេសដើម្បីស្វែងយល់ពីបទពិសោធន៍លើករណីនេះ។

**ខ.ការផ្តល់សេវាអ៊ិនធឺណិត៖** បង្កើតគោលការណ៍ណែនាំដល់ក្រុមហ៊ុនផ្តល់សេវាអ៊ិនធឺណិតត្រូវមានយន្តការអនុវត្តនីតិវិធីទាំងឡាយ ដើម្បីរាយការណ៍ កំណត់ប្រភេទរូបភាព និងសម្ភារអាសអាភាសកុមារ(CSAM) និងលុបចេញរូបភាព និងសម្ភារអាសអាភាសកុមារពីប្រព័ន្ធផ្ទុកទិន្នន័យមេ(Server)ក្នុងប្រទេសកម្ពុជា។ ហើយធ្វើការសហការទំនាក់ទំនងជាមួយអ្នកផ្តល់សេវានៅអន្តរជាតិដើម្បីបិទ ឬដកចេញពីការ អាចទាញយកបានសម្ភារ (CSAM)។ ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ក្រសួងកិច្ចការនារី និងក្រសួងនិងស្ថាប័នពាក់ព័ន្ធ គួរបង្កើតគោលការណ៍រួមកំណត់ពីខ្លឹមសារខុសច្បាប់ពាក់ព័ន្ធនឹង (CSAM)ដែលដាក់បង្ហាញលើអ៊ិនធឺណិត ឬបណ្តាញសង្គមដែលត្រូវបានចាត់ទុកថាប៉ះពាល់ដល់សីលធម៌ ប្រពៃណីជាតិ សាសនា។ លើកកម្ពស់ការយល់ដឹងពីផលប៉ះពាល់ដោយសារ(CSAM)និងការឆ្លើយតបបញ្ហា(CSAM) ទាន់ពេលវេលា(ទាំងរដ្ឋាភិបាល និងក្រុមហ៊ុន)។ លើកកម្ពស់ការយល់ដឹងអំពីការប៉ះពាល់ទាក់ទងនឹង (CSAM) មាននៅក្នុងបណ្តាញមេ ដែលធ្វើឱ្យកុមារដែលធ្លាប់រងគ្រោះ អាចរងគ្រោះឡើងវិញនៅពេលដែលរូបភាពត្រូវបានគេមើល ហើយវាក៏ផ្តល់ឱ្យជនល្មើសមានលទ្ធភាពទទួលបានរូបភាព និងបន្តចែកចាយសម្ភារ (CSAM) បន្តទៀត។ បង្កើនការផ្សព្វផ្សាយ និងបញ្ជ្រាបការយល់ដឹងអំពីបទល្មើស និងហានិភ័យបច្ចេកវិទ្យាព័ត៌មាន។ បង្កើតជា Postter Video spot សម្រាប់ផ្សព្វផ្សាយពី CSAM (CNCC and MoI)។ ជំរុញ និងលើកទឹក

៥៩-១

ចិត្តឱ្យក្រុមហ៊ុនផ្តល់សេវាអ៊ិនធឺណិត ណែនាំដល់អ្នកប្រើប្រាស់ឧបករណ៍ចែកចាយអ៊ិនធឺណិត ដែលមានសុវត្ថិភាពចំពោះកុមារ(Parental control)។ ជំរុញ និងលើកទឹកចិត្តឱ្យក្រុមហ៊ុនផ្តល់សេវាអ៊ិនធឺណិត ពិនិត្យលទ្ធភាពក្នុងការដាក់នូវឧបករណ៍ដើម្បីគ្រប់គ្រងនិងផ្តល់សញ្ញាហាមឃាត់មិនឱ្យប្រើប្រាស់ (Website) អាសអាភាស ឬអាសអាភាសកុមារ។

**គ.យុត្តិធម៌ព្រហ្មទណ្ឌ៖** ពង្រីកបណ្តាញប្រឆាំងបទល្មើសបច្ចេកវិទ្យានៅថ្នាក់ក្រោមជាតិដើម្បីបង្ការ ទប់ស្កាត់ និងឆ្លើយតបករណី (CSAM) បានទាន់ពេលវេលា។ ពង្រឹងសមត្ថភាពមន្ត្រីជំនាញនៅថ្នាក់ជាតិ និងក្រោមជាតិរបស់នាយកដ្ឋានប្រឆាំងបទល្មើសបច្ចេកវិទ្យា និងអង្គភាពជំនាញពាក់ព័ន្ធ។ បង្កើនធនធាន និងកិច្ចសហប្រតិបត្តិការជាមួយដៃគូជាតិ និងអន្តរជាតិនានាក្នុងការឆ្លើយតបបញ្ហា(CSAM)ឱ្យកាន់តែមានប្រសិទ្ធភាព (រាប់បញ្ចូលទាំងលើកកម្ពស់ការយល់ដឹងអំពីការស៊ើបអង្កេត(CSAM)។ បង្កើនទំនាក់ទំនងជិតស្និទ្ធជាមួយការិយាល័យកណ្តាលជាតិទំនាក់ទំនងនគរបាលអន្តរជាតិ(NCB)ភ្នំពេញដែលនឹងផ្តល់ជំនួយក្នុងការកំណត់ដំណើរការចែកចាយ(CSAM) និងធ្វើឱ្យប្រាកដថារូបភាព (CSAM) ទាំងនោះអាចយកមកអនុវត្តវិធានការច្បាប់អន្តរជាតិ។

**ឃ.សង្គម៖** លើកកម្ពស់ការយល់ដឹងអំពីការប្រើប្រាស់បណ្តាញសង្គម ការកំណត់ភាពឯកជន និងការរក្សារូបភាព និងរក្សាសុវត្ថិភាពព័ត៌មានបុគ្គល ការដាក់លេខសម្ងាត់ជាដើម។ បណ្តុះបណ្តាលអំពីការរាយការណ៍ពីភាពរងគ្រោះនិងអាចធ្វើការលុបចោលមាតិការំលោភបំពាននៅលើបណ្តាញព័ត៌មានសង្គម។ បង្កើនយុទ្ធនាការផ្សព្វផ្សាយក្នុងសហគមន៍ និងសាលារៀនអំពីបញ្ហាប្រឈមក្នុងការប្រើប្រាស់បណ្តាញព័ត៌មានសង្គម និងទីតាំង ឬប្រព័ន្ធអាចរាយការណ៍បាន។ ឪពុកម្តាយ និងអ្នកថែទាំកុមារ គួរមានការយល់ដឹងពីការប្រើប្រាស់អ៊ិនធឺណិតដែលនឹងភ្ជាប់ទំនាក់ទំនងកុមារនៅក្នុងពិភពបច្ចេកវិជ្ជារបស់ពួកគេ។ សង្គមស៊ីវិល និងក្រុមហ៊ុនឯកជន ធ្វើយុទ្ធនាការផ្សព្វផ្សាយតាមទូរទស្សន៍ ឬតាមប្រព័ន្ធផ្សព្វផ្សាយសង្គមទៅតាមសាលារៀននិងសហគមន៍ឱ្យបានយល់ដឹងអំពីបញ្ហាអាចកើតមានគ្រោះថ្នាក់តាមអ៊ិនធឺណិត និងផ្សព្វផ្សាយដល់អ្នកប្រើប្រាស់ពីរបៀបបង្ការចៀសវាងពីជនខិលខូចនៅក្នុងប្រព័ន្ធអនឡាញ។ ផ្សព្វផ្សាយអំពីប្រព័ន្ធរាយការណ៍ (Internet Hotlines) និងកន្លែងដែលអាចរាយការណ៍បានទៅដល់គ្រួសារ អ្នកថែទាំកុមារ សហគមន៍ទូទៅ និងសាលារៀន។ លើកកម្ពស់ការចូលរួមរបស់កុមារក្នុងការរៀបចំផែនការសកម្មភាពដើម្បីឆ្លើយតបទៅនឹងបញ្ហាប្រឈមជុំវិញការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ។

## ១.២. ស្ថានភាពការកេងប្រវ័ញ្ចផ្លូវភេទតាមប្រព័ន្ធអនឡាញ

ការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ(OCSE) សំដៅទៅលើការប្រើប្រាស់អ៊ីនធឺណិតជាមធ្យោបាយដើម្បីកេងប្រវ័ញ្ចផ្លូវភេទលើកុមារ ដែលមានសញ្ញាណរួមបញ្ចូលការកេងប្រវ័ញ្ចកើតឡើងនៅពេលដែលកុមារស្ថិតក្នុងខណៈណាមួយ តាមទម្រង់ផលិតសម្ភារំលោភបំពានផ្លូវភេទលើកុមារ (CSAM) អំពើលួងលោមតាមប្រព័ន្ធអនឡាញ(Online Grooming) អំពើផ្ញើសារបែបរំលោភបំពានផ្លូវភេទ(Sexting) អំពើគំរាមខាងផ្លូវភេទ (Sextortion) និងអំពើផ្សាយបន្តផ្ទាល់ការរំលោភបំពានផ្លូវភេទលើកុមារ(Live Online Child Sexual Abuse)[12]។ ជាសកល ការទទួលបានសេវាអ៊ិនធឺណិត កុំព្យូទ័រផ្ទាល់ខ្លួន និងទូរស័ព្ទដៃវៃឆ្លាតតម្លៃសមរម្យ កំពុងកើនឡើងយ៉ាងឆាប់រហ័សនៅក្នុងសហគមន៍ក្រីក្រ និងងាយរងគ្រោះ គឺរៀងរាល់៥នាទីគេហទំព័របានបង្ហាញពីកុមារម្នាក់ត្រូវបានគេកេងប្រវ័ញ្ចផ្លូវភេទ ហើយមានអ្នកចុះឈ្មោះប្រើប្រាស់គេហទំព័រដែលផ្សព្វផ្សាយរូបភាពរំលោភបំពានផ្លូវភេទលើកុមារជាង១.៩លាននាក់ និងមានការរាយការណ៍ជាង ១៨.៤ លានទាក់ទងនឹងការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាម

[12] WePROTECT. (2016).

ប្រព័ន្ធអនឡាញ។[13] កំណើនឡើងករណីពាក់ព័ន្ធកុមារមានអាយុត្រឹម៤ឆ្នាំ ទន្ទឹមនឹងនេះមានរូបថត និងវីដេអូចំនួន ១-៨ម៉ឺនជាមធ្យមត្រូវបានរកឃើញ និងរឹបអូសនៅពេលមានការចាប់ខ្លួនជនល្មើស។ ក្នុងតំបន់អាស៊ីអាគ្នេយ៍មាន ប្រជាជន៧៥%មានទូរស័ព្ទដៃវៃឆ្លាត និងមានលើសពី២ភាគ៣ នៃអ្នកប្រើប្រាស់អ៊ិនធឺណិតកំពុងប្រើប្រាស់គេហទំព័រ បណ្តាញសង្គម និងកម្មវិធីសូហ្វវែរ តាមរយៈឧបករណ៍ចល័ត។[14] យ៉ាងហោចណាស់ មានអ្នកប្រើប្រាស់បណ្តាញ ទំនាក់ទំនងសង្គមចំនួន ៧៥០លាននាក់នៅទូទាំងតំបន់។[15]

ការភ្ជាប់ប្រព័ន្ធអ៊ិនធឺណិតចល័ត បណ្តាញទំនាក់ទំនងសង្គម និងការប្រើប្រាស់បច្ចេកវិទ្យាបានពង្រីកខ្លួន យ៉ាងខ្លាំងនៅក្នុងប្រទេសកម្ពុជាក្នុងអំឡុងពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ហើយនិន្នាការនេះត្រូវបានព្យាករណ៍ថានឹង បន្តកើនឡើង។ នាពេលបច្ចុប្បន្ននេះនៅកម្ពុជាមានអ្នកប្រើប្រាស់លេខទូរស័ព្ទចល័តចំនួន២០.៧៤៧.៣៩២ លេខ និងទូរស័ព្ទអចល័តចំនួន ៥៣.២៤៧ លេខ ប្រើប្រាស់អ៊ីនធឺណិតចល័តប្រមាណ ១៤.៩៩២.០៣១ ភ្ជាប់ប្រព័ន្ធនិង អ៊ីនធឺណិតអចល័តចំនួន ២៤២.២៧៨ ភ្ជាប់ប្រព័ន្ធ។ មានអ្នកប្រើ Facebook ចំនួន ១០.៦៥៦.០០០ Messenger ចំនួន ៨.០១៦.០០០ Instagram ចំនួន ៧១៨.៨០០ Linkedin ចំនួន ៣៨៤.៩០០។ ក្នុងចំណោមអ្នកប្រើប្រាស់ Facebook ចំនួន ១០.៦៥៦.០០០ មានប្រុសចំនួន ៥៧.៤% ស្រីចំនួន ៤២.៦% ក្នុងនោះមានអ្នកប្រើប្រាស់ បណ្តាញសង្គមដែលមិនទាន់គ្រប់អាយុមានចំនួនប្រមាណ ៨៣១នាក់។[16]

ក្រាហ្វិកទី១៖ចំនួនអ្នកប្រើប្រាស់ Facebook នៅកម្ពុជា




ការតភ្ជាប់ប្រព័ន្ធអ៊ិនធឺណិត កុំព្យូទ័រផ្ទាល់ខ្លួន និងទូរស័ព្ទដៃវៃឆ្លាត នៅតាមសហគមន៍មានចំណូលទាប មាន អត្ថប្រយោជន៍ផ្នែកសង្គម និងសេដ្ឋកិច្ចជាច្រើន។ ទោះបីជាយ៉ាងណា ក៏បង្កនូវហានិភ័យគួរឱ្យកត់សម្គាល់ផងដែរ ចំពោះកុមារ និងមនុស្សវ័យក្មេង ដែលអាចជាអ្នកប្រើប្រាស់អ៊ិនធឺណិតល្បឿនលឿន និងចូលរួមសកម្មក្នុងបណ្តាញ ទំនាក់ទំនងសង្គម។ ការរីករាលដាលនៃការតភ្ជាប់ប្រព័ន្ធអ៊ិនធឺណិតនេះ បានបង្កលក្ខណៈកាន់តែងាយស្រួល និង ឆាប់រហ័សដល់អ្នកប្រើប្រាស់អ៊ិនធឺណិត អាចទទួលបានសម្ភារពាក់ព័ន្ធនឹងការរំលោភបំពានផ្លូវភេទលើកុមារ និង ធ្វើឱ្យមានការផ្សព្វផ្សាយសម្ភារ គាំទ្រអ្នកនិយមផ្លូវភេទលើកុមារក្នុងចំណោមភេទទីបី និងអ្នកដែលមានចំណាប់

[13] NCMEC. (2018)
[14] We are Social. (2017).
[15] *Ibid*.
[16] ប្រភពទិន្នន័យ៖ និយ័តករទូរគមនាគមន៍កម្ពុជា ខែមេសា ឆ្នាំ២០២០

អារម្មណ៍ផ្លូវភេទជាមួយកុមារ[17]។ ដោយភាពធូរថ្លៃនៃសេវាអ៊ិនធឺណិត និងល្បឿនលឿននៃការតភ្ជាប់ទំនាក់ទំនងកាន់តែកើនឡើង ដូច្នេះការផ្ទេរទិន្នន័យទំហំធំអាចធ្វើបានងាយស្រួលក្នុងចំណោមអ្នកប្រើប្រាស់។ ការពង្រីកការប្រើប្រាស់ប្រព័ន្ធអ៊ិនធឺណិតជាការបង្កបរិយាកាសក៏ងាយស្រួលដល់ជនខិលខូចនៅព្រំដែនកម្ពុជា តំបន់ និងអន្តរជាតិ[18] ដោយហេតុនេះ  នាំឱ្យយល់ខុសអំពីភាពស្របច្បាប់ចំពោះអ្នកដែលមានចំណាប់អារម្មណ៍ផ្លូវភេទជាមួយកុមារ[19]។ ស្របពេលដែលមិនដឹងអំពីចំនួនជនរងគ្រោះនៃការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញជាសាកល ចំនួនគេហទំព័រដែលមានសម្ភារពាក់ព័ន្ធនឹងការរំលោភបំពានផ្លូវភេទលើកុមារ ត្រូវបានដកស្រង់ថា បានកើនឡើងចំនួន១៤៧% នៅចន្លោះឆ្នាំ២០១២ និង២០១៤ ប៉ុណ្ណោះ ហើយការប៉ាន់ស្មាននាពេលបច្ចុប្បន្ន បង្ហាញឱ្យឃើញថាបញ្ហានេះគួរឱ្យកត់សម្គាល់ដែលកំពុងកើនឡើងយ៉ាងឆាប់រហ័ស[20]។

របាយការណ៍ស្ដីពី(CSAM)ពាក់ព័ន្ធនឹងកម្ពុជាត្រូវបានបញ្ជូនដោយស្វ័យប្រវត្តិទៅកាន់ភ្នាក់ងារស៊ើបអង្កេតសន្តិសុខមាតុភូមិ(HSI)របស់សហរដ្ឋអាមេរិកដែលមានទីតាំងនៅក្នុងស្ថានទូតសហរដ្ឋអាមេរិកក្នុងរាជធានីភ្នំពេញ។ បន្ទាប់មកភ្នាក់ងារ(HSI)នៅក្នុងរាជធានីភ្នំពេញ ទទួលខុសត្រូវលើការទាញយករបាយការណ៍ទាំងនេះ និងកំណត់ថាតើករណីណាដែលមានលក្ខណៈបន្ទាន់បំផុតនិងអាចចាត់វិធានការបាននៅថ្នាក់ប្រទេស។ ក្នុងរយៈពេលប្រាំមួយឆ្នាំកន្លងទៅមានការកើនឡើងជាលំដាប់នូវចំនួនរបាយការណ៍ទាំងនេះទៅកាន់(HSI)នៅរាជធានីភ្នំពេញជាពិសេសគឺនៅឆ្នាំ២០១៨។ស្របពេលដែលមិនទាន់មានចំនួនពេញលេញសម្រាប់ឆ្នាំ២០១៨នៅឡើយ  សេចក្ដីរាយការណ៍អំពី(CSAM) សម្រាប់ប្រទេសកម្ពុជា ចាប់ពីខែមករា ដល់ថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០១៩ បានបង្ហាញនូវការកើនឡើងចំនួន៤៩០% ពីឆ្នាំ២០១៧។ មានន័យថា ក្នុងអំឡុងពេល១១ខែ ដើមឆ្នាំ២០១៩ (NCMEC)បានបញ្ជូនរបាយការណ៍ករណី(CSAM)ចំនួន ១២៣.៨៩៦ ទៅកាន់(HSI)នៅរាជធានីភ្នំពេញ ច្រើនជាងចំនួនរបាយការណ៍ដែលត្រូវបញ្ជូនក្នុងអំឡុងពេល៦ឆ្នាំ បូកបញ្ចូលគ្នាទៀត(សូមមើលតារាងខាងក្រោម)។

តារាងទី១៖តារាងរបាយការណ៍ស្ដីពី(CSAM)ពាក់ព័ន្ធនឹងកម្ពុជា

| ឆ្នាំ | របាយការណ៍ VPN | របាយការណ៍ជាព័ត៌មាន | សរុប |
|---|---|---|---|
| ២០១៣ | ៣៧០ | មិនពាក់ព័ន្ធ | ៣៧០ |
| ២០១៤ | ៤.៧៥៩ | មិនពាក់ព័ន្ធ | ៤.៧៥៩ |
| ២០១៥ | ៥.២៩២ | ២៤.១៣៣ | ២៩.៤២៥ |
| ២០១៦ | ៩.២២១ | ២១.០៨៣ | ៣០.៣០៤ |
| ២០១៧ | ៤.៨៣២ | ២០.៥០០ | ២៥.៣៣២ |
| ២០១៨* | ៣៥.៩១៣ | ៨៧.៩៨៣ | ១២៣.៨៩៦ |

*ឆ្នាំ ២០១៨ – ត្រឹមថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០១៨

[17]Elliott &Ashfield. (2011); Kierkegaard. (2008).
[18]ក្រសួងយុត្តិធម៌សហរដ្ឋអាមេរិក(ឆ្នាំ២០១៨) នគរបាលអន្តរជាតិ(ឆ្នាំ២០១៨)
[19]Kloss, et al. (2014).
[20]UNICEF. (2016).

## ១.៣. ទំនាក់ទំនងរវាងផែនការសកម្មភាព និងក្របខ័ណ្ឌគតិយុត្តពាក់ព័ន្ធ

ផែនការសកម្មភាពដើម្បីបង្ការ ទប់ស្កាត់ និងឆ្លើយតបការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ ឆ្នាំ២០២១-២០២៥ មានសង្គតិភាពជាមួយផែនការសកម្មភាពទប់ស្កាត់ និងឆ្លើយតបចំពោះអំពើហិង្សាលើកុមារ ឆ្នាំ២០១៧-២០២១ ក្របខណ្ឌគំរូឆ្លើយតបថ្នាក់ជាតិ(MNR)នៃសេចក្តីថ្លែងការណ៍សកម្មភាពសកល(WePROTECT) ឆ្នាំ២០១៥ សេចក្តីថ្លែងការណ៍របស់ប្រមុខរដ្ឋប្រទេសជាសមាជិកអាស៊ាន ស្តីពីការការពារកុមារពីគ្រប់ទម្រង់នៃអំពើកេងប្រវ័ញ្ចនិងរំលោភបំពានផ្លូវភេទក្នុងអាស៊ានឆ្នាំ២០១៩ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៩-២០២៣ យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា ២០៣០ និងឯកសារពាក់ព័ន្ធជាតិ និងអន្តរជាតិផ្សេងទៀត។

ផែនការសកម្មភាពនេះ ជាផែនទីតម្រង់ផ្លូវឱ្យអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ ក្រសួង ស្ថាប័នពាក់ព័ន្ធ អង្គការមិនមែនរដ្ឋាភិបាល រដ្ឋបាលថ្នាក់ក្រោមជាតិ និងវិស័យឯកជនរៀបចំផែនការសកម្មភាពប្រចាំឆ្នាំ និងថវិកាកម្មវិធី ដើម្បីធ្វើឱ្យសម្រេចបាននូវចំណុចដៅនៃសូចនាករដែលបានកំណត់នៅក្នុងផែនការសកម្មភាព ដើម្បីបង្ការ ទប់ស្កាត់ និងឆ្លើយតបការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ ២០២១-២០២៥។

## ១.៤. ដំណើរការរៀបចំផែនការសកម្មភាព

ដំណើរការរៀបចំផែនការសកម្មភាព ដើម្បីបង្ការ ទប់ស្កាត់ និងឆ្លើយតបការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ ឆ្នាំ២០២១-២០២៥ បានចាប់ផ្តើមដំណើរការពីខែឧសភា ដល់ខែតុលា ឆ្នាំ២០២០ ដែលដឹកនាំរៀបចំដោយអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ ដោយមានជំនួយពីទីប្រឹក្សាបច្ចេកទេស ក្រោមការផ្តល់បច្ចេកទេស និងថវិកាពីអង្គការសកម្មភាពដើម្បីកុមារ និងអង្គការដែនដីមនុស្ស-ហូឡង់ដ៍ រួមទាំងឧបត្ថម្ភថវិកាពីរាជរដ្ឋាភិបាល។ ការរៀបចំផែនការសកម្មភាពផ្អែកលើក្របខណ្ឌឆ្លើយតបថ្នាក់ជាតិគំរូ (MNR) នៃ WePROTECT ឆ្នាំ២០១៥ វិធានការឆ្លើយតបទាំង៧នៃសេចក្តីថ្លែងការណ៍របស់ប្រមុខរដ្ឋសមាជិកអាស៊ានឆ្នាំ២០១៩ និងអនុសាសន៍នៃរបាយការណ៍វិភាគស្ថានភាពដំបូងស្តីពីការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ ផែនការសកម្មភាពទប់ស្កាត់និងឆ្លើយតបចំពោះអំពើហិង្សាលើកុមារ ឯកសារពាក់ព័ន្ធកិច្ចការពារកុមារ និងការប្រមូលធាតុចូលពីអ្នកពាក់ព័ន្ធនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិតាមរយៈការប្រជុំក្រុមបច្ចេកទេស និងការធ្វើសិក្ខាសាលា។

សេចក្តីព្រាងសូន្យផែនការសកម្មភាពដើម្បីបង្ការ ទប់ស្កាត់ និងឆ្លើយតបការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ ត្រូវបានអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិកម្ពុជា និងអ្នកពាក់ព័ន្ធផ្តល់ធាតុចូល និងដាក់ជូនកិច្ចប្រជុំក្រុមការងារបច្ចេកទេស OCSE ពិនិត្យ និងកែសម្រួល នៅកិច្ចប្រជុំនាខេត្តកោះកុង ចំនួនពីរថ្ងៃគឺពីថ្ងៃទី៦-៧ ខែកក្កដា ឆ្នាំ២០២០ និងសិក្ខាសាលាពិគ្រោះយោបល់ជាមួយកុមារនិងយុវជននៅថ្ងៃទី០៦ ខែសីហា ឆ្នាំ២០២០ រាជធានីភ្នំពេញ ដើម្បីប្រមូលធាតុចូលសម្រាប់សេចក្តីព្រាងទី១។ សេចក្តីព្រាងទី១នៃផែនការ បានដាក់ជូនសិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិ នៅថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០២០ និងប្រជុំក្រុមការងារបច្ចេកទេស OCSE នៅថ្ងៃទី១៣-១៤ ខែតុលា ឆ្នាំ២០២០ នៅខេត្តកំពត និងនៅថ្ងៃទី២៨-២៩ ខែធ្នូ ឆ្នាំ២០២០ នៅខេត្តពោធិ៍សាត់ ក្នុងគោលបំណងប្រមូលធាតុចូលបន្ថែម ដើម្បីរៀបចំកែសម្រួលសេចក្តីព្រាងចុងក្រោយសម្រាប់ដាក់ជូនថ្នាក់ដឹកនាំគណៈកម្មាធិការកិច្ចការពារកុមារថ្នាក់ជាតិ និងថ្នាក់ដឹកនាំ ក.ជ.ក ពិនិត្យ និងកែសម្រួលសេចក្តីព្រាងចុងក្រោយមុនដាក់ជូនប្រធានក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារពិនិត្យនិងអនុម័ត។ ៥៨-១

# ២.  ខ្ទង់នភាព និងបញ្ហាប្រឈម

## ២.១.ខ្ទង់នភាព

ដោយមើលឃើញនូវផលប៉ះពាល់ និងបញ្ហាប្រឈមដែលបានកើតឡើងក្នុងពេលថ្មីៗនេះ ព្រះរាជាណាចក្រកម្ពុជា បានចូលជាសមាជិកនៃប្រទេសភាពជាដៃគូសកល ដើម្បីលុបបំបាត់អំពើហិង្សាលើកុមារ (Path Finding Country) នៅថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១៩ នេះ។ មិនតែប៉ុណ្ណោះ ព្រះរាជាណាចក្រកម្ពុជា ក៏បានចុះហត្ថលេខាលើសេចក្តីថ្លែងការណ៍ (WePROTECT) នៅទីក្រុងអាប៊ុយដាប៊ី ក្នុងឆ្នាំ២០១៥ ពាក់ព័ន្ធនឹងសកម្មភាពទប់ស្កាត់ ការរំលោភបំពាន និងកេងប្រវ័ញ្ចកុមារតាមប្រព័ន្ធអនឡាញដែលមានក្រសួងមហាផ្ទៃជាអ្នកសម្របសម្រួល។ ការវិវត្តជាវិជ្ជមាននេះស្របគ្នាទៅនឹងផែនការសកម្មភាពទប់ស្កាត់ និងឆ្លើយតបចំពោះអំពើហិង្សាលើកុមារ ឆ្នាំ២០១៧-២០២១ ដែលបានលើកទឹកចិត្តឱ្យមានសកម្មភាពទប់ស្កាត់អំពើហិង្សា និងកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ។ បន្ថែមពីនេះទៀត ប្រមុខរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងប្រមុខដឹកនាំរដ្ឋជាសមាជិកនៃប្រទេសអាស៊ានទាំងអស់ បានអនុម័តលើសេចក្តីថ្លែងការណ៍ស្តីពីការការពារកុមារពីគ្រប់ទម្រង់នៃអំពើកេងប្រវ័ញ្ច និងរំលោភបំពានផ្លូវភេទក្នុងអាស៊ាន នៅកិច្ចប្រជុំកំពូលថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០១៩ ក្នុងគោលបំណងអំពាវនាវឱ្យរដ្ឋជាសមាជិកអាស៊ានទាំងអស់ប្រើប្រាស់បទដ្ឋានកម្រិតខ្ពស់ ដើម្បីការពារកុមារទាំងអស់នៅក្នុងអាស៊ានពីការកេងប្រវ័ញ្ច និងរំលោភបំពានផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ។

ដើម្បីដោះស្រាយបញ្ហាប្រឈមខាងលើ អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ សហការជាមួយអង្គការដៃគូ ធ្វើការវិភាគស្ថានភាពជំបូងនេះដើម្បីប៉ាន់ប្រមាណផលប៉ះពាល់លើការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញនៅកម្ពុជាតាមនីតិវិធីមួយចំនួន ដូចជា៖ ប៉ាន់ប្រមាណទីកន្លែង និងវិធីសាស្ត្រដែលជាកត្តាជំរុញកុមារឱ្យស្ថិតក្នុងស្ថានភាពងាយរងគ្រោះថ្នាក់ ព្រមទាំងបានកំណត់នូវសមត្ថភាព និងភាពខ្វះចន្លោះនៃគោលនយោបាយជាតិ លិខិតបទដ្ឋានគតិយុត្ត យុត្តិធម៌ព្រហ្មទណ្ឌ សេវាសង្គម និងវិស័យឯកជន។ ការប៉ាន់ប្រមាណនេះធ្វើឡើងក្នុងគោលបំណងកំណត់នូវ "អនុសាសន៍ដែលអាចធ្វើបានដោយផ្អែកលើភស្តុតាង" ដើម្បីឆ្លើយតបទៅនឹងការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ នៅក្នុងបរិបទនៃកម្ពុជា ដែលអនុលោមទៅតាមគំរូនៃការឆ្លើយតបថ្នាក់ជាតិ (WePROTECT-MNR) ដោយរៀនពីការអនុវត្តល្អៗនៅកម្រិតថ្នាក់ជាតិនិងថ្នាក់អន្តរជាតិ។

នៅក្នុងការឆ្លើយតបចំពោះសម្ភារពាក់ព័ន្ធនឹងការរំលោភបំពានផ្លូវភេទលើកុមារ រាជរដ្ឋាភិបាល ឧស្សាហកម្មអ៊ីនធឺណិត និងអង្គការមិនមែនរដ្ឋាភិបាលមួយចំនួន បានកំពុងធ្វើការងារដើម្បីធ្វើឱ្យកុមារមានសុវត្ថិភាពនៅតាមប្រព័ន្ធអនឡាញ តាមរយៈការឆ្លើយតបចំពោះការគំរាមកំហែងនៃការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ។ ក្រសួងស្ថាប័ន និងអង្គការមិនមែនរដ្ឋាភិបាលសំខាន់ៗមួយចំនួនដែលកំពុងធ្វើការងារដើម្បីឆ្លើយតបនឹងការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញរួមមាន៖ ក្រសួងមហាផ្ទៃ ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ អង្គការដែនដីមនុស្ស-ហូឡង់ប្រចាំកម្ពុជា អង្គការសកម្មភាពដើម្បីកុមារ មូលនិធិអន្តរជាតិនៃបណ្តាញរាយការណ៍បន្ទាន់តាមប្រព័ន្ធអ៊ិនធឺណិត (INHOPE)[21] មជ្ឈមណ្ឌលជាតិការពារកុមារបាត់ខ្លួន និងរងគ្រោះដោយការកេងប្រវ័ញ្ច (NCMEC)[22] មូលនិធិឃ្លាំមើលតាមប្រព័ន្ធអ៊ិនធឺណិត (IWF)[23] និង Cybertip.ca[24]។

[21] INHOPE Foundation. *At A Glance.* Accessed 20 Nov 2018 from, http://www.inhope.org/gns/who-we-are/at-a-glance.aspx
[22] NSVRC. Accessed 20 Nov, 2018 from, https://www.nsvrc.org/organizations/60
[23] Internet World Foundation. Who We Are. Accessed 20 Nov, 2018 from, https://www.iwf.org.uk/what-we-do/who-we-are
[24] Cybertip.ca. *About us.* Accessed 17 Nov, 2018 from, https://www.cybertip.ca/app/en/about

## ២.២.បញ្ហាប្រឈម

**គោលនយោបាយ និងអភិបាលកិច្ច៖** សេចក្តីព្រាងច្បាប់ស្តីពីបទល្មើសបច្ចេកវិទ្យាព័ត៌មាន ដែលបានកំណត់និយមន័យនិងបន្ថែមទោសប្បញ្ញត្តិពាក់ព័ន្ធការរំលោភបំពាននិងកេងប្រវ័ញ្ចផ្លូវភេទលើគ្រប់រូបភាពដោយរាប់បញ្ចូលទាំងការលួងលោមតាមប្រព័ន្ធអ៊ិនធឺណិតជាបទល្មើស និងលិខិតបទដ្ឋានគតិយុត្តដើម្បីអនុវត្តច្បាប់នេះមិនទាន់បានពិនិត្យកែសម្រួលនិង ចងក្រងនៅឡើយ។ ផ្អែកលើច្បាប់ពាក់ព័ន្ធកម្ពុជាមិនទាន់បានកំណត់គោលការណ៍ណែនាំ និងកំណត់ស្តង់ដារ ដែលអាចរក្សាកំណត់ត្រាទិន្នន័យ IP (IP Assignment Log Preservation) ដែលតម្រូវឱ្យក្រុមហ៊ុនផ្តល់សេវាអ៊ិនធឺណិតទាំងអស់បង្កើតគោលនយោបាយការពារកុមារ ឆ្លើយតបឱ្យបានឆាប់រហ័សនឹងការទទួលខុសត្រូវចំពោះមាតិកា(CSAM)នៅក្នុងសេវូបករណ៍(Servers)របស់ក្រុមហ៊ុននៅឡើយ។ កម្ពុជាមិនទាន់បានបង្កើតយន្តការមួយដែលមានសមាសភាពចូលរួមពីក្រសួងមហាផ្ទៃ ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងវប្បធម៌ ក្រសួងយុត្តិធម៌ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងព័ត៌មាន និងក្រសួងកិច្ចការនារី ដែលធ្វើការដាក់លាក់លើ(OCSE)ក្នុងការដោះស្រាយឱ្យបានទាន់ពេលវេលានៅឡើយ។

**យុត្តិធម៌ព្រហ្មទណ្ឌ៖**កង្វះទិន្នន័យអំពីករណីទាក់ទងនឹងការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញដែលត្រូវបានរាយការណ៍ពីភ្នាក់ងារ ឬស្ថាប័នអនុវត្តច្បាប់មូលដ្ឋានត្រូវបានលើកឡើងថា ជាបញ្ហាប្រឈមគួរឱ្យកត់សម្គាល់ក្នុងអំឡុងពេល១០ឆ្នាំមកនេះ។ បញ្ហានេះ គឺជាបញ្ហាជាក់ស្តែង ជាពិសេសនៅអាស៊ីដោយសារប្រទេសជាច្រើនគ្មានយន្តការរាយការណ៍ជាតិដែលមានលក្ខណៈរួមបញ្ចូលជាមួយនឹងទីភ្នាក់ងារ ឬស្ថាប័នជាតិ អនុវត្តច្បាប់។ ទន្ទឹមនឹងនេះការយល់ដឹង និងសមត្ថភាពរបស់ទីភ្នាក់ងារ ឬស្ថាប័នជាតិ អនុវត្តច្បាប់នៅមានកម្រិត បន្ថែមពីនេះនៅខ្វះចំណេះដឹងអំពីឧបករណ៍ (ICT)និងនិន្នាការនៃបច្ចេកវិទ្យា ខ្វះធនធាននៅសហគមន៍មូលដ្ឋាន និងកិច្ចសហការជាមួយអ្នកជំនាញឯកទេស និងធនធានអន្តរជាតិ ហើយពឹងផ្អែកជ្រុលលើវិធីសាស្ត្រស៊ើបអង្កេតផ្ទាល់តាមបែបប្រពៃណី និងមិនទាន់មានអភិក្រមដែលគិតគូរអំពីជនរងគ្រោះ។

**ការផ្តល់សេវាអ៊ីនធឺណិត៖** ចំពោះការលេចឡើងនូវព័ត៌មានផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ និយ័តករទូរគមនាគមន៍កម្ពុជា (ន.ទ.ក) ជាសេនាធិការរបស់ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ មិនអាចធ្វើការទប់ស្កាត់បានទេ។ ទោះជាបង្កើតក្រុមការងារដើម្បីតាមដានបញ្ហានេះក៏នឹងមិនទទួលបានជោគជ័យបានដែរ ដោយសារខ្លឹមសារទាំងនោះត្រូវបានបង្ហោះក្នុងគេហទំព័រ ឬបណ្តាញសង្គមដូចជា(Facebook)ក្រុមហ៊ុននេះមាន(Server)របស់ខ្លួនដំណើរការនៅក្រៅព្រះរាជាណាចក្រកម្ពុជា។ ដូច្នេះ ន.ទ.ក. មិនអាចធ្វើការឆ្លើយតប និងបិទមាតិកាជាក់លាក់ណាមួយនៅក្នុងបណ្តាញសង្គមបានទេ ព្រោះប្រសិនបើបិទ ចាំបាច់ត្រូវបិទបណ្តាញសង្គមទាំងអស់ យ៉ាងណាមិញ ន.ទ.ក. ជឿជាក់ថាបញ្ហាដែល(OCSE) បានលើកឡើងពីការកេងប្រវ័ញ្ចលើកុមារតាមប្រព័ន្ធអនឡាញ ពិតជាមានសារៈសំខាន់ណាស់ដោយសារគ្រួសារ និងកុមារមិនទាន់មានការយល់ដឹងអំពីផលប៉ះពាល់នៃការចែករំលែកព័ត៌មានឯកជនរបស់កុមារទាក់ទងនឹងផ្លូវភេទតាមប្រព័ន្ធអនឡាញនៅឡើយ។

**ការយល់ដឹងរបស់សហគមន៍ និងសង្គម៖** ការយល់ដឹងអំពីការប្រើប្រាស់បណ្តាញសង្គម ការកំណត់ភាពឯកជន ការរក្សារូបភាព រក្សាសុវត្ថិភាពព័ត៌មានបុគ្គល និងការដាក់លេខសម្ងាត់ជាដើមនៅមានកម្រិត។ ចំណែកការបណ្តុះបណ្តាលអំពីការរាយការណ៍អំពីភាពរងគ្រោះ និងអាចធ្វើការលុបចោលមាតិការំលោភបំពាននៅលើបណ្តាញព័ត៌មានសង្គមមិនទាន់បានដំណើរការពេញលេញ។ ដោយឡែកយុទ្ធនាការផ្សព្វផ្សាយក្នុងសហគមន៍ និងសាលារៀនអំពីបញ្ហាប្រឈមក្នុងការប្រើសប្រាស់បណ្តាញព័ត៌មានសង្គម និងទីតាំង ឬប្រព័ន្ធអាចរាយការណ៍មិនទាន់មាន

កម្មវិធីច្បាស់លាស់។ ឪពុកម្តាយនិងអ្នកថែទាំកុមារ មិនទាន់យល់ដឹងអំពីផលប៉ះពាល់នៃការប្រើប្រាស់អ៊ិនធឺណិតដែលនឹងភ្ជាប់ទំនាក់ទំនងកុមារនៅក្នុងពិភពបច្ចេកវិទ្យា។

ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ សង្គមស៊ីវិល និងក្រុមហ៊ុនឯកជនត្រូវធ្វើយុទ្ធនាការផ្សព្វផ្សាយតាមទូរទស្សន៍ ឬតាមប្រព័ន្ធផ្សព្វផ្សាយសង្គមទៅតាមសាលារៀន និងសហគមន៍ឱ្យបានយល់ដឹងអំពីបញ្ហាអាចកើតមានគ្រោះថ្នាក់តាមអ៊ិនធឺណិតនៅមានកម្រិត ឯការផ្សព្វផ្សាយដល់អ្នកប្រើប្រាស់ពីរបៀបបង្ការចៀសវាងពីជនខិលខូចនៅក្នុងប្រព័ន្ធអនឡាញ ព្រមទាំង ការផ្សព្វផ្សាយអំពីប្រព័ន្ធរាយការណ៍(Internet Hotlines) និងកន្លែងដែលអាចរាយការណ៍បានទៅដល់គ្រួសារ អ្នកថែទាំកុមារ សហគមន៍ទូទៅ និងសាលារៀនក៏នៅមានកម្រិតផងដែរ។

## ៣. គោលដៅយុទ្ធសាស្ត្រ និងលទ្ធផលរំពឹងទុក

ដើម្បីដោះស្រាយបញ្ហាប្រឈមខាងលើ ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ សហការជាមួយអ្នកពាក់ព័ន្ធបានរៀបចំផែនការសកម្មភាពដើម្បីបង្ការ ទប់ស្កាត់ និងឆ្លើយតបការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញនៅកម្ពុជាឆ្នាំ២០២១-២០២៥ មានគោលដៅយុទ្ធសាស្ត្រអាទិភាពចំនួន៦គឺ៖ ១.ពង្រឹងប្រសិទ្ធភាពការអនុវត្តគោលនយោបាយនិងអភិបាលកិច្ច ២.លើកកម្ពស់យុត្តិធម៌ព្រហ្មទណ្ឌ ៣.លើកកម្ពស់វិធានការបង្ការ ទប់ស្កាត់ និងស្តារនីតិសម្បទាជនរងគ្រោះដោយអំពើកេងប្រវ័ញ្ចផ្លូវតាមប្រព័ន្ធអនឡាញ ៤.ពង្រឹងសុវត្ថិភាពសហគមន៍ពីការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ ៥.ពង្រឹងលក្ខន្តិកៈសម្រាប់ការផ្តល់សេវាអ៊ីនធឺណិត ៦.បង្កើនការផ្សព្វផ្សាយ និងការយល់ដឹងត្រឹមត្រូវអំពីបញ្ហាការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ។

| គោលដៅយុទ្ធសាស្ត្រទី១៖ | ពង្រឹងប្រសិទ្ធភាពការអនុវត្តគោលនយោបាយ និងអភិបាលកិច្ច |
|---|---|
| គោលបំណង៖ | សិក្សាស្រាវជ្រាវ ធ្វើការវិភាគ និងតាមដានស្ថានភាពហានិភ័យនៃការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញដើម្បីបង្កើតនិងពិនិត្យកែសម្រួលលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនានាឱ្យមានលក្ខណៈទូលំទូលាយ និងមានប្រសិទ្ធភាពក្នុងការស៊ើបអង្កេតជនល្មើស និងធានាបាននូវសុវត្ថិភាព ទំនុកចិត្តនិងយុត្តិធម៌សម្រាប់ជនរងគ្រោះ និងងាយរងគ្រោះ។ |
| លទ្ធផលរំពឹងទុក៖ | ថ្នាក់ដឹកនាំក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ កម្លាំងសេវាសង្គម[25] និងអ្នកពាក់ព័ន្ធ មានអភិបាលកិច្ច និងគណនេយ្យភាពលើការបង្ការ ទប់ស្កាត់ និងឆ្លើយតបចំពោះការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ និងក្រៅប្រព័ន្ធអនឡាញនៅក្នុងគ្រួសារនិងសហគមន៍។ |

### ចង្កោមសកម្មភាព និងសកម្មភាពអនុវត្ត៖

| ល.រ | ចង្កោមសកម្មភាព | សកម្មភាពអនុវត្ត | | សូចនាករលទ្ធផល |
|---|---|---|---|---|
| ១.១ | ពង្រឹងអភិបាលកិច្ច និងគណនេយ្យភាពចំពោះ (OCSE) | ១.១.១ | ពិនិត្យកែសម្រួលតួនាទី និងភារកិច្ចគណៈកម្មការការពារកុមារថ្នាក់ជាតិដោយបញ្ចូលការទទួលខុសត្រូវលើការឆ្លើយតប(OCSE) | (១)អភិបាលកិច្ច និងគណនេយ្យភាព ក្នុងការបង្ការ ទប់ស្កាត់ និង |

[25] **កម្លាំងសេវាសង្គម** សំដៅដល់អ្នកទាំងឡាយណាដែលធ្វើការដើម្បីធានាបាននូវការអភិវឌ្ឍសុខុមាលភាពរបស់ជនរងគ្រោះ និងជនងាយរងគ្រោះ ទាំងមន្ត្រីរាជការ (នគរបាល គ្រូបង្រៀន ពេទ្យ មន្ត្រីសង្គមកិច្ច...)ទាំងបុគ្គលិកអង្គការមិនមែនរដ្ឋាភិបាល ទោះជាអ្នកទាំងនោះមានអាជីព ឬគ្មានអាជីព ហើយធ្វើការដោយយកកម្រៃ ឬមិនយកកម្រៃក៏ដោយ។ ។

| ល.រ | ចង្កោមសកម្មភាព | សកម្មភាពអនុវត្ត | | សូចនាករលទ្ធផល |
|---|---|---|---|---|
| | | ១.១.២ | ពិនិត្យ និងកែសម្រួលតួនាទីភារកិច្ចយន្តការកិច្ចការពារកុមារនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីបង្ការ ទប់ស្កាត់ និងឆ្លើយតប(OCSE) | ឆ្លើយតប(OCSE)ត្រូវបានពង្រឹងនិងពង្រីក ទាំងនៅថ្នាក់ជាតិ និងនៅថ្នាក់ក្រោមជាតិ |
| | | ១.១.៣ | បញ្ចូលបញ្ហា(OCSE)ក្នុងផែនការអភិវឌ្ឍន៍ ៥ឆ្នាំ និងកម្មវិធីវិនិយោគ៣ឆ្នាំរំកិលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ | |
| | | ១.១.៤ | បង្កើតគោលការណ៍ណែនាំរួម ស្តីពីខ្លឹមសារខុសច្បាប់ពាក់ព័ន្ធ(CSAM)ដែលដាក់បង្ហាញលើអ៊ិនធឺណិត ឬបណ្តាញសង្គមដែលនាំឱ្យប៉ះពាល់ដល់សីលធម៌ និងប្រពៃណីជាតិ | |
| | | ១.១.៥ | បង្កើតគោលការណ៍ណែនាំរួម ស្តីពីខ្លឹមសារខុសច្បាប់ពាក់ព័ន្ធនឹង(CSAM)ដែលដាក់បង្ហាញលើអ៊ិនធឺណិត ឬបណ្តាញសង្គមដែលនាំឱ្យប៉ះពាល់ដល់សាសនា | |
| ១.២ | សិក្សាស្រាវជ្រាវ វិភាគ និងតាមដានអំពីការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ (OCSE) | ១.២.១ | ពិនិត្យបទល្មើសរូបភាពសម្ភារអាសអាភាសកុមារតាមខ្លឹមសារ(CSAM)និង(CSEM)ដែលមានចែងនៅក្នុងច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ | (២)លទ្ធផលនៃការសិក្សាស្រាវជ្រាវ ការវិភាគនិងតាមដាន (OCSE)ត្រូវបានធ្វើជាធាតុចូលសម្រាប់រៀបចំគោលនយោបាយ ច្បាប់ លិខិតបទដ្ឋានគតិយុត្ត |
| | | ១.២.២ | ដាក់បញ្ចូលខ្លឹមសារពាក់ព័ន្ធនឹង(OCSE)ទៅក្នុងសេចក្តីព្រាងច្បាប់ស្តីពីបទល្មើសបច្ចេកវិទ្យាព័ត៌មាន | |
| | | ១.២.៣ | ដឹកនាំ និងសម្របសម្រួលការសិក្សាសកលស្តីពីការបញ្ឈប់គ្រោះថ្នាក់នៃ(OCSE) | |
| | | ១.២.៤ | ធ្វើការសិក្សាស្រាវជ្រាវស៊ីជម្រៅអំពី(OCSE) នៅកម្ពុជា | |
| | | ១.២.៥ | បង្កើតឧបករណ៍ និងប្រព័ន្ធត្រួតពិនិត្យ តាមដាន និងវាយតម្លៃលើការអនុវត្តផែនការសកម្មភាព(OCSE) | |
| ១.៣ | បង្កើតច្បាប់ និងលិខិតបទដ្ឋានគតិយុត្តឱ្យមានប្រសិទ្ធភាពក្នុងការស៊ើបអង្កេតជនល្មើស និងធានាសុវត្ថិភាព យុត្តិធម៌ដល់កុមាររងគ្រោះ (OCSE) | ១.៣.១ | ពន្លឿនការអនុម័តច្បាប់ស្តីពីបទល្មើសបច្ចេកវិទ្យាព័ត៌មាន | (៣)ច្បាប់ស្តីពីបទល្មើសបច្ចេកវិទ្យាព័ត៌មាន និងលិខិតបទដ្ឋានគតិយុត្តត្រូវបានអនុម័ត និងអនុវត្តដើម្បីផ្តន្ទាទោសជនល្មើស និងផ្តល់យុត្តិធម៌ដល់ជនរងគ្រោះយសារ(OCSE) |
| | | ១.៣.២ | ផ្សព្វផ្សាយ និងអនុវត្តច្បាប់ស្តីពីបទល្មើសបច្ចេកវិទ្យាព័ត៌មាន | |
| | | ១.៣.៣ | បង្កើតលិខិតបទដ្ឋានគិយុត្តដើម្បីអនុវត្តច្បាប់ស្តីពីបទល្មើសបច្ចេកវិទ្យាព័ត៌មាន | |
| | | ១.៣.៤ | បង្កើតលិខិតបទដ្ឋានគតិយុត្តស្តីពីសុវត្ថិភាពកុមារក្នុងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន | |
| | | ១.៣.៥ | បង្កើតសេចក្តីណែនាំស្តីពីការកំណត់ | |

| ល.រ | ចង្កោមសកម្មភាព | សកម្មភាពអនុវត្ត | | សូចនាករលទ្ធផល |
|---|---|---|---|---|
| | | | ស្តង់ដារសម្រាប់រក្សាកំណត់ត្រាទិន្នន័យ IP (IP Assignment Log Preservation) | |
| | | ១.៣.៦ | រៀបចំប្រកាសស្តីពីកិច្ចការពារកុមារតាមប្រព័ន្ធអនឡាញ | |
| | | ១.៣.៧ | បង្កើតសេចក្តីណែនាំស្តីពីកិច្ចការពារកុមារតាមអនឡាញក្នុងបរិបទកូវីដ | |
| | | ១.៣.៨ | បង្កើតគោលការណ៍ណែនាំរួមស្តីពីខ្លឹមសារខុសច្បាប់ពាក់ព័ន្ធ(CSAM)ដែលដាក់បង្ហាញលើអ៊ិនធឺណិត ឬបណ្តាញសង្គមដែលនាំឱ្យប៉ះពាល់ដល់សីលធម៌ និងប្រពៃណីជាតិ | |
| | | ១.៣.៩ | បង្កើតគោលការណ៍ណែនាំរួមស្តីពីខ្លឹមសារខុសច្បាប់ពាក់ព័ន្ធនឹង(CSAM)ដែលដាក់បង្ហាញលើអ៊ិនធឺណិត ឬបណ្តាញសង្គមដែលនាំឱ្យប៉ះពាល់ដល់សាសនា | |

**គោលដៅយុទ្ធសាស្ត្រទី២៖ លើកកម្ពស់យុត្តិធម៌ព្រហ្មទណ្ឌ**

**គោលបំណង៖** ជំរុញការឆ្លើយតបប្រកបដោយប្រសិទ្ធភាពនៃការស៊ើបអង្កេត និងផ្តន្ទាទោសបទល្មើសផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ ព្រមទាំងពង្រឹងសមត្ថភាពមន្ត្រីអនុវត្តច្បាប់នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

**លទ្ធផលរំពឹងទុក៖** ការស៊ើបអង្កេតនិងការផ្តន្ទាទោសចំពោះបទល្មើសផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ និងការគ្រប់គ្រងជនល្មើសប្រកបដោយប្រសិទ្ធភាព និងជោគជ័យ។

## ចង្កោមសកម្មភាព និងសកម្មភាព៖

| ល.រ | ចង្កោមសកម្មភាព | សកម្មភាពអនុវត្ត | | សូចនាករលទ្ធផល |
|---|---|---|---|---|
| ២.១ | ពង្រឹងការអនុវត្តច្បាប់ និងសហប្រតិបត្តិការអន្តរជាតិពាក់ព័ន្ធនឹង(OCSE) | ២.១.១ | ពង្រឹង និងពង្រីកយន្តការប្រឆាំងបទល្មើសបច្ចេកវិទ្យាព័ត៌មានដែលមានស្រាប់នៅថ្នាក់ក្រោមជាតិដើម្បីបង្ការ ទប់ស្កាត់ និងឆ្លើយតបករណី(CSAM)បានទាន់ពេលវេលា | (១)យន្តការប្រឆាំងបទល្មើសបច្ចេកវិទ្យាព័ត៌មានត្រូវបានពង្រឹងសមត្ថភាព និងមានធនធានគ្រប់គ្រាន់ដើម្បីបង្ការ ទប់ស្កាត់ និងឆ្លើយតបនឹង(OCSE) |
